រៀបរៀងដោយ លឹម ផល្គុន និង សែន ពិសិដ្ឋ
បរិញ្ញាបត្រផ្នែកគណិតវិទ្យា

# គណិតវិទ្យាជ្រើសរើស

## សម្រាប់សិស្សពូកែថ្នាក់ទី

# ១០

$i^2 = -1$

$\frac{-b \pm \sqrt{b^2 - 4ac}}{2a}$

- រួមមាន
- មេរៀនសង្ខេប
- លំហាត់គំរូ
- លំហាត់អនុវត្តន៍

$\sqrt{a^2} = |a|$

$\tan\varphi = \frac{\sin\varphi}{\cos\varphi}$

$Z$ $\beta$ $\mu$ $\sqrt{2}$ $\pm\infty$

$\sin^2\varphi + \cos^2\varphi = 1$ $\perp$

$\pi$ $\sqrt{a}\times\sqrt{b} = \sqrt{ab}$

$\frac{\sqrt{a}}{\sqrt{b}} = \sqrt{\frac{a}{b}}$

$\frac{1}{\sin^2\phi} = 1 + \cot^2\phi$

រក្សាសិទ្ធិដោយ លឹម ផល្គុន

ស្របតាមកម្មវិធីសិក្សាថ្មី

# គណៈកម្មការនិពន្ធ និង រៀបរៀង

លោក លឹម ផល្គុន

លោក សែន ពិសិដ្ឋ

# គណៈកម្មការត្រួតពិនិត្យបច្ចេកទេស

| | |
|---|---|
| លោក លឹម អុន | លោក អ៊ឹង សំណាង |
| លោកស្រី ទុយ រីណា | លោក ទិត្យ ម៉េង |
| លោក នន់ សុខណា | លោក ព្រឹម សុនិត្យ |

# គណៈកម្មការត្រួតពិនិត្យអក្ខរាវិរុទ្ធ

លោក លឹម មិគ្គសិរ

## ការិយកុំព្យូទ័រ

លោក អ៊ឹង សំណាង

កញ្ញា លី គុណ្ណាកា

## រចនាជំព័រ និង ក្រាប

លោក ព្រំ ម៉ាឡា

*មេរៀនសង្ខេប*

# ចំនួនពិត និង ប្រព័ន្ធរង្វាស់

## ១_ចំនួនពិត

*ក. បន្ទាត់ចំនួនពិត*




-ចំនុច **O** ត្រូវនឹងចំនួន **0** ។

-គ្រប់ចំនុចនៅផ្នែកវិជ្ជមានហើយមានចម្ងាយ **s** ពីចំនុច **O** ត្រូវគ្នានឹងចំនួនវិជ្ជមាន **s** ។

-គ្រប់ចំនុចនៅផ្នែកអវិជ្ជមានហើយមានចម្ងាយ **s** ពីចំនុច **O** ត្រូវគ្នានឹងចំនួនអវិជ្ជមាន $-s$

*ខ. ការប្រៀបធៀបចំនួនពិត*

-ចំនួនពិត **b** ធំជាងចំនួនពិត **a** ឬ ចំនួនពិត **a** តូចជាងចំនួនពិត **b** ត្រូវបានគេកំណត់សរសេរ $b > a$ ឬ $a < b$ ។

-បើ **a** វិជ្ជមាននោះ $a > 0$ ។

-បើ **a** អវិជ្ជមាននោះ $a < 0$ ។

គេអាចប្រៀបធៀបចំនួនពិតតាមលក្ខណៈខាងក្រោម :

-ចំពោះគ្រប់ចំនួនពិត $\mathbf{a}$ និង $\mathbf{b}$ គេអាចបានទំនាក់ទំនងមួយក្នុងចំណោមទំនាក់ទំនងបី គឺ $\mathbf{a<b}$ , $\mathbf{a=b}$ , $\mathbf{a>b}$ ។

-បើ $\mathbf{a>b}$ និង $\mathbf{b>c}$ នាំឱ្យ $\mathbf{a>c}$ ។

-បើ $\mathbf{a<b}$ និង $\mathbf{b<c}$ នាំឱ្យ $\mathbf{a<c}$ ។

-បើ $\mathbf{a=b}$ និង $\mathbf{b=c}$ នាំឱ្យ $\mathbf{a=c}$ ។

-បើ $\mathbf{a>b}$ សមមូល $\mathbf{a-b>0}$ ។

-បើ $\mathbf{a<b}$ សមមូល $\mathbf{a-b<0}$ ។

*គ. តម្លៃដាច់ខាត*

-តម្លៃដាច់ខាតនៃចំនួនពិត $\mathbf{a}$ កំណត់តាងដោយ $|\mathbf{a}|$ ។

-គ្រប់ចំនួនពិត $\mathbf{a}$ គេមាន $|\mathbf{a}|\geq \mathbf{0}$

-តម្លៃ $|\mathbf{a}|=\mathbf{0}$ លុះត្រាតែ $\mathbf{a=0}$

-ការបញ្ចេញតម្លៃដាច់ខាត $|\mathbf{a}| = \left[\begin{array}{lll} \mathbf{a} & \text{បើ} & \mathbf{a\geq 0} \\ \mathbf{-a} & \text{បើ} & \mathbf{a<0} \end{array}\right.$

## ២_គន្សោមរ៉ាឌីកាល់

*ក.ផលគុណ និង ផលចែកឫសការេ*

ចំពោះគ្រប់ចំនួនពិត $\mathbf{a>0}$ និង $\mathbf{b>0}$ គេមាន :

1. $\sqrt{\mathbf{a}}\times\sqrt{\mathbf{b}}=\sqrt{\mathbf{ab}}$

2. $\dfrac{\sqrt{\mathbf{a}}}{\sqrt{\mathbf{b}}}=\sqrt{\dfrac{\mathbf{a}}{\mathbf{b}}}$

*ខ.ប្រៀបធៀបឫសការេនៃចំនួនវិជ្ជមានពីរ*

ចំពោះគ្រប់ចំនួនពិត $a > 0$ និង $b > 0$ គេមាន :

1. $a < b \Leftrightarrow \sqrt{a} < \sqrt{b}$

2. $a > b \Leftrightarrow \sqrt{a} > \sqrt{b}$

*គ.ការបំបាត់រ៉ាឌីកាល់ពីភាគបែង*

ចំពោះគ្រប់ចំនួនពិត $a > 0$ និង $b > 0$ ដែល $a \neq b$ គេមាន :

$(\sqrt{a}-\sqrt{b})(\sqrt{a}+\sqrt{b}) = a - b$ ដូចនេះគេមានសមភាព :

1. $\dfrac{c}{\sqrt{a}+\sqrt{b}} = \dfrac{(\sqrt{a}-\sqrt{b})c}{(\sqrt{a}+\sqrt{b})(\sqrt{a}-\sqrt{b})} = \dfrac{(\sqrt{a}-\sqrt{b})c}{a-b}$

2. $\dfrac{c}{\sqrt{a}-\sqrt{b}} = \dfrac{(\sqrt{a}+\sqrt{b})c}{(\sqrt{a}-\sqrt{b})(\sqrt{a}+\sqrt{b})} = \dfrac{(\sqrt{a}+\sqrt{b})c}{a-b}$

*ឃ.ការសម្រួលរ៉ាឌីកាល់ពីរជាន់*

ចំពោះគ្រប់ចំនួនពិត $a > 0$ និង $b > 0$ ដែល $a \geq b$ គេមាន :

$\sqrt{a+b\pm 2\sqrt{ab}} = \sqrt{(\sqrt{a}\pm\sqrt{b})^2} = \sqrt{a}\pm\sqrt{b}$ ។

## ៣_ប្រព័ន្ធរាប់

*ក.ប្រព័ន្ធគោល* $10$

$$(a_n a_{n-1}.....a_2 a_1 a_0)_{10} = a_n \times 10^n + a_{n-1}\times 10^{n-1} + .... + a_2 \times 10^2 + a_1 \times 10 + a_0$$

*ខ.ប្រព័ន្ធគោល* $2$

$$(a_n a_{n-1}.....a_2 a_1 a_0)_2 = a_n \times 2^n + a_{n-1}\times 2^{n-1} + .... + a_2 \times 2^2 + a_1 \times 2 + a_0$$ ៗ

# កម្រងលំហាត់ជ្រើសរើស

1. គេឱ្យ $a , b , c$ ជាបីចំនួនពិតមិនសូន្យ ។

ចូរកំណត់តម្លៃដែលអាចនៃកន្សោម $A=\frac{a}{|a|}+\frac{b}{|b|}+\frac{c}{|c|}$ ?

2. ចូរកំណត់លក្ខខណ្ឌ $a$ និង $b$ ដើម្បីឱ្យគេបានសមភាពដូចខាងក្រោម :

$$\left|\frac{a-b}{a}\right|=\frac{b-a}{a} \quad ?$$

3. គេឱ្យ $a , b , c$ ជាបីចំនួនពិតផ្ទៀងផ្ទាត់

$$(3a+6)^2+\left|\frac{1}{4}b-10\right|+|c+3|=0$$

ចូរកំណត់តម្លៃនៃ $a^{10}+bc$ ?

4. គេឱ្យ $a , b , c$ ជាបីចំនួនពិតដែល $a<b<c$ ។

ចូរកំនត់តម្លៃតូចបំផុតនៃកន្សោម : $y=|x-a|+|x-b|+|x-c|$

5. គេដឹងថា $c>1$ ហើយគេមាន $x=\frac{\sqrt{c+2}-\sqrt{c+1}}{\sqrt{c}-\sqrt{c-1}}$ , $y=\frac{\sqrt{c+2}-\sqrt{c+1}}{\sqrt{c+1}-\sqrt{c}}$

និង $z=\frac{\sqrt{c}-\sqrt{c-1}}{\sqrt{c+2}-\sqrt{c+1}}$ ។

ចូរស្រាយបញ្ជាក់ថា $x<y<z$ ?

6. គេឱ្យ $x$ ជាចំនួនពិតមួយ ។ គេយក $A=\frac{-1+3x}{1+x}-\frac{\sqrt{|x|-2}+\sqrt{2-|x|}}{|2-x|}$

ចូរបង្ហាញថា $A$ ជាចំនួនគត់ ។

7. គេឱ្យ $\mathbf{x=\dfrac{\sqrt{7}+\sqrt{3}}{\sqrt{7}-\sqrt{3}}}$ និង $\mathbf{y=\dfrac{\sqrt{7}-\sqrt{3}}{\sqrt{7}+\sqrt{3}}}$

ចូរកំណត់តម្លៃ $\mathbf{S=x^4+y^4+(x+y)^4}$ ។

8. គណនាតម្លៃនៃកន្សោម :

$$\mathbf{P=(\sqrt{10}+\sqrt{11}+\sqrt{12})(\sqrt{10}+\sqrt{11}-\sqrt{12})(\sqrt{10}-\sqrt{11}+\sqrt{12})(\sqrt{10}-\sqrt{11}-\sqrt{12})}$$

9.គណនា $\mathbf{N=\dfrac{\sqrt{15}+\sqrt{35}+\sqrt{21}+5}{\sqrt{3}+2\sqrt{5}+\sqrt{7}}}$

10. សម្រួល $\mathbf{A=\sqrt{2+\sqrt{-2+2\sqrt{5}}}-\sqrt{2-\sqrt{-2+2\sqrt{5}}}}$

11. គេដឹងថា $\mathbf{x=\sqrt{19-8\sqrt{3}}}$ ។

គណនាតម្លៃ $\mathbf{A=\dfrac{x^4-6x^3-2x^2+18x+23}{x^2-8x+15}}$

12. សម្រួល $\mathbf{y=\sqrt[3]{a+\dfrac{a+8}{3}\sqrt{\dfrac{a-1}{3}}}+\sqrt[3]{a-\dfrac{a+8}{3}\sqrt{\dfrac{a-1}{3}}}}$ ដែល $\mathbf{a\geq 1}$ ។

13. គេឱ្យចំនួន $\mathbf{A=\overline{21a78}_{10}}$ និង $\mathbf{B=\overline{87b12}_{10}}$ ដែល $\mathbf{a}$ និង $\mathbf{b}$ ជាលេខ ។

បើ $\mathbf{A\times 4=B}$ នោះចូរកំណត់គ្រប់គូ $\mathbf{(a,b)}$ ?

14.គេឱ្យ $\mathbf{a}$ , $\mathbf{b}$ , $\mathbf{c}$ ជាលេខ ។

គេតាង $\mathbf{x=\overline{ab}_{10}}$ , $\mathbf{y=x-10}$ និង $\mathbf{z=\overline{ccc}_{10}}$

គេដឹងថា $\mathbf{x.y=z}$ ។ ចូរកំណត់គូ $\mathbf{(a,b,c)}$

15. គេឱ្យចំនួន $\mathbf{n=\overline{aabb}_{10}}$ ដែល $\mathbf{a}$ និង $\mathbf{b}$ ជាលេខ ។

ក. ចូរបង្ហាញថាគ្រប់លេខ $\mathbf{a}$ និង $\mathbf{b}$ ចំនួន $\mathbf{n}$ ចែកដាច់នឹង $\mathbf{11}$ ជានិច្ច ។

ខ. គេយក $q=\frac{n}{11}$ ។ បង្ហាញថាបើ $q$ ចែកដាច់នឹង $11$ នោះមានគូ$(a , b)$តែមួយគត់ដែល $n$ ជាការេប្រាកដ ?

16. គេឱ្យចំនួន $n=\overline{aaaaaa}_{10}$ ដែល $a=\{1,2,3,4,5,6,7,8,9\}$

ក. ចូរស្រាយថា $n$ ចែកដាច់នឹង 7 ជានិច្ច ។

ខ. ចូរកំណត់គ្រប់លេខ $a$ ដើម្បីឱ្យ $n$ មានតួចែកយ៉ាងតិចមួយជាការេប្រាកដធំជាង $1$ ។

17. គេឱ្យចំនួន $n=\overline{aaabbb}_{10}$ ដែល $a\neq b$ និង $a ,b$ ជាលេខ ។

ក.ចូរសរសេរ $n$ ជាទម្រង់ពន្លាត រួចបង្រួម ។

ខ. កំណត់គ្រប់គូ $(a , b )$ ដែលធ្វើឱ្យ $n$ ចែកដាច់នឹង 7 ។

18. គេឱ្យចំនួន $n=\overline{abcd}_{2}$ ក្នុងប្រព័ន្ធរបាប់គោល 2 ដែល $a , b , c , d\in\{0,1\}$ ។

ក. ចូរសរសេរ $n$ ជាទម្រង់ពន្លាត ។

ខ. បើ $a=b=c=1$ នោះចូរកំណត់ $d$ ដើម្បីឱ្យ $n$ ចែកដាច់នឹង $5$ ។

គ. បើ $a=b=d=1$ នោះចូរកំណត់ $c$ ដើម្បីឱ្យ $n$ ចែកដាច់នឹង $3$ ។

ឃ. បើ $a=c=d=1$ នោះចូរកំណត់ $b$ ដើម្បីឱ្យ $n$ ចែកដាច់នឹង $11$ ។

19.គេឱ្យចំនួន $n=1100101_{2}$ (ក្នុងប្រព័ន្ធគោល $2$)

និងចំនួន $p=\overline{14285b}_{10}$ (ក្នុងប្រព័ន្ធគោល $10$)

ក.ចូរសរសេរ $n$ ទៅជាចំនួនក្នុងប្រព័ន្ធគោល $10$ ។

ខ.កំណត់លេខ $b$ ដើម្បីឱ្យ $\frac{p\times b+1}{9(n+6)+10}$ ជាចំនួនគត់ ?

20. គេឱ្យចំនួន $\mathbf{m = \overline{21a7b}_{10}}$ និង $\mathbf{n = \overline{b7a12}_{10}}$

ចូរកំណត់លេខ **a** និង **b** ដើម្បីឱ្យ $\mathbf{\frac{n}{m} = 4}$ ?

រៀបរៀងដោយ **លឹម ផល្គុន**

Tel : 017 768 246

www.mathtoday.wordpress.com

## លំហាត់ទី១

គេឱ្យ $\mathbf{a , b , c}$ ជាបីចំនួនពិតមិនសូន្យ ។

ចូរកំណត់តម្លៃដែលអាចនៃកន្សោម $\mathbf{A = \frac{a}{|a|} + \frac{b}{|b|} + \frac{c}{|c|}}$ ?

## ដំណោះស្រាយ

កំណត់តម្លៃដែលអាចនៃកន្សោម $\mathbf{A = \frac{a}{|a|} + \frac{b}{|b|} + \frac{c}{|c|}}$

-បើ $\mathbf{a > 0 , b > 0 , c > 0}$ (វិជ្ជមានទាំងបី)

គេបាន $\mathbf{A = \frac{a}{a} + \frac{b}{b} + \frac{c}{c} = 1 + 1 + 1 = 3}$ ។

-បើ $\mathbf{a < 0 , b < 0 , c < 0}$ (អវិជ្ជមានទាំងបី)

គេបាន $\mathbf{A = \frac{a}{-a} + \frac{b}{-b} + \frac{c}{-c} = -1 - 1 - 1 = -3}$ ។

-បើក្នុងចំណោម $\mathbf{a , b , c}$ មានអវិជ្ជមានមួយ និង វិជ្ជមានពីរ

គេបាន $\mathbf{A = -1 + 1 + 1 = 1}$ ។

-បើក្នុងចំណោម $\mathbf{a , b , c}$ មានអវិជ្ជមានពីរ និង វិជ្ជមានមួយ

គេបាន $\mathbf{A = -1 - 1 + 1 = -1}$ ។

ដូចនេះតម្លៃដែលអាចនៃ $\mathbf{A}$ គឺ $\mathbf{-3 , -1 , 1}$ និង $\mathbf{3}$ ។

## លំហាត់ទី២

ចូរកំណត់លក្ខខណ្ឌ **a** និង **b** ដើម្បីឱ្យគេបានសមភាពដូចខាងក្រោម :

$$\left|\frac{a-b}{a}\right| = \frac{b-a}{a} \quad ?$$

## ដំណោះស្រាយ

កំណត់លក្ខខណ្ឌ **a** និង **b**

សមភាពដែលឱ្យ $\left|\frac{a-b}{a}\right| = \frac{b-a}{a}$ ពិតលុះត្រាតែ :

$a \neq 0$ និង $\frac{a-b}{a} \leq 0$

$\Leftrightarrow 1-\frac{b}{a} \leq 0$

$\Leftrightarrow \quad \frac{b}{a} \geq 1$

ដូចនេះគេមានលក្ខខណ្ឌ **a** និង **b** គឺ $\frac{b}{a} \geq 1$ និង $a \neq 0$ ។

## លំហាត់ទី៣

គេឱ្យ **a , b , c** ជាបីចំនួនពិតផ្សេងផ្ទាត់ $(3a+6)^2+|\frac{1}{4}b-10|+|c+3|=0$

ចូរកំណត់តម្លៃនៃ $a^{10}+bc$ ?

## ដំណោះស្រាយ

កំណត់តម្លៃនៃ $a^{10}+bc$

គេមាន $(3a+6)^2+|\frac{1}{4}b-10|+|c+3|=0$

យើងឃើញថាអង្គខាងឆ្វេងនៃសមីការសុទ្ធតែជាចំនួនមិនអវិជ្ជមាន ។

ហេតុនេះយើងត្រូវតែបាន $\begin{cases} 3a+6=0 \\ \frac{1}{4}b-10=0 \\ c+3=0 \end{cases}$

គេទាញ $a=-2$ , $b=40$ , $c=-3$

ដូចនេះ $a^{10}+bc=(-2)^{10}+(40)(-3)=1024-120=904$ ។

## លំហាត់ទី៤

គេឱ្យ $a , b , c$ ជាបីចំនួនពិតដែល $a < b < c$ ។

ចូរកំនត់តម្លៃតូចបំផុតនៃកន្សោម : $y = |x-a| + |x-b| + |x-c|$

## ដំណោះស្រាយ

កំនត់តម្លៃតូចបំផុត

គេមាន $y = |x-a| + |x-b| + |x-c|$

-ករណី $x \le a$

គេបាន $y = (a-x) + (b-x) + (c-x) \ge (b-a) + (c-a)$

-ករណី $a < x \le b$

គេបាន

$$y = (x-a) + (b-x) + (c-x) = (b-a) + (c-x) \ge (b-a) + (c-b) = c-a$$

-ករណី $b < x \le c$

គេបាន

$$y = (x-a) + (x-b) + (c-x) = (x-a) + (c-b) > (b-a) + (c-b) = c-a$$

-ករណី $c < x$

គេបាន

$$y = (x-a) + (x-b) + (x-c) > (b-a) + (c-b) + (x-c) > c-a$$

ដូចនេះ $y_{min} = c-a$ ដែលត្រូវនឹង $x = b$ ។

## លំហាត់ទី៥

គេដឹងថា $c>1$ ហើយគេមាន $x=\dfrac{\sqrt{c+2}-\sqrt{c+1}}{\sqrt{c}-\sqrt{c-1}}$ , $y=\dfrac{\sqrt{c+2}-\sqrt{c+1}}{\sqrt{c+1}-\sqrt{c}}$

និង $z=\dfrac{\sqrt{c}-\sqrt{c-1}}{\sqrt{c+2}-\sqrt{c+1}}$ ។

ចូរស្រាយបញ្ជាក់ថា $x<y<z$ ?

## ដំណោះស្រាយ

ស្រាយបញ្ជាក់ថា $x<y<z$

គេមាន $x=\dfrac{\sqrt{c+2}-\sqrt{c+1}}{\sqrt{c}-\sqrt{c-1}}$

$$=\frac{[(\sqrt{c+2})^2-(\sqrt{c+1})^2](\sqrt{c}+\sqrt{c-1})}{(\sqrt{c+2}+\sqrt{c+1})[(\sqrt{c})^2-(\sqrt{c-1})^2]}$$

$$=\frac{\sqrt{c}+\sqrt{c-1}}{\sqrt{c+2}+\sqrt{c+1}}$$

$$y=\frac{\sqrt{c+2}-\sqrt{c+1}}{\sqrt{c+1}-\sqrt{c}}=\frac{[(\sqrt{c+2})^2-(\sqrt{c+1})^2](\sqrt{c+1}+\sqrt{c})}{(\sqrt{c+2}+\sqrt{c+1})[(\sqrt{c+1})^2-(\sqrt{c})^2]}$$

$$=\frac{\sqrt{c+1}+\sqrt{c}}{\sqrt{c+2}+\sqrt{c+1}}$$

គេទាញបាន $x<y$ ព្រោះ $\sqrt{c}+\sqrt{c-1}<\sqrt{c+1}+\sqrt{c}$ ។

ហើយ $z=\dfrac{\sqrt{c}-\sqrt{c-1}}{\sqrt{c+2}-\sqrt{c+1}}=\dfrac{\sqrt{c+2}+\sqrt{c+1}}{\sqrt{c}+\sqrt{c-1}}$

ដោយ $\sqrt{c}+\sqrt{c-1}<\sqrt{c+1}+\sqrt{c}<\sqrt{c+2}+\sqrt{c+1}$ នោះ $x<y<z$ ពិត ។

## លំហាត់ទី៦

គេឱ្យ $x$ ជាចំនួនពិតមួយ ។ គេយក $A=\frac{-1+3x}{1+x}-\frac{\sqrt{|x|-2}+\sqrt{2-|x|}}{|2-x|}$

ចូរបង្ហាញថា $A$ ជាចំនួនគត់ ។

## ដំណោះស្រាយ

បង្ហាញថា $A$ ជាចំនួនគត់

$A=\frac{-1+3x}{1+x}-\frac{\sqrt{|x|-2}+\sqrt{2-|x|}}{|2-x|}$ មានន័យ លុះត្រាតែ $\begin{cases}|x|-2\geq 0\\ 2-|x|\geq 0\\ |2-x|\neq 0\end{cases}$

សមមូល $\begin{cases}|x|=2\\ x\neq 2\end{cases}$ នាំឱ្យ $x=-2$

ចំពោះ $x=-2$ គេបាន $A=\frac{-1-6}{1-2}-\frac{0}{4}=7$

ដូចនេះ $A=7$ ជាចំនួនគត់ ។

## លំហាត់ទី៧

គេឱ្យ $\mathbf{x}=\dfrac{\sqrt{7}+\sqrt{3}}{\sqrt{7}-\sqrt{3}}$ និង $\mathbf{y}=\dfrac{\sqrt{7}-\sqrt{3}}{\sqrt{7}+\sqrt{3}}$

ចូរកំណត់តម្លៃ $\mathbf{S}=\mathbf{x}^4+\mathbf{y}^4+(\mathbf{x}+\mathbf{y})^4$ ។

## ដំណោះស្រាយ

កំណត់តម្លៃ $\mathbf{S}=\mathbf{x}^4+\mathbf{y}^4+(\mathbf{x}+\mathbf{y})^4$

គេមាន $\mathbf{x}=\dfrac{\sqrt{7}+\sqrt{3}}{\sqrt{7}-\sqrt{3}}=\dfrac{(\sqrt{7}+\sqrt{3})^2}{\sqrt{7}^2-\sqrt{3}^2}=\dfrac{10+2\sqrt{21}}{4}$

និង $\mathbf{y}=\dfrac{\sqrt{7}-\sqrt{3}}{\sqrt{7}+\sqrt{3}}=\dfrac{(\sqrt{7}-\sqrt{3})^2}{7-3}=\dfrac{10-2\sqrt{21}}{4}$

គេបាន $\mathbf{x}+\mathbf{y}=5$ និង $\mathbf{xy}=1$

គេមាន 
$$\begin{aligned}\mathbf{S}&=\mathbf{x}^4+\mathbf{y}^4+(\mathbf{x}+\mathbf{y})^4\\&=(\mathbf{x}^2+\mathbf{y}^2)^2-2\mathbf{x}^2\mathbf{y}^2+(\mathbf{x}+\mathbf{y})^4\\&=\left[(\mathbf{x}+\mathbf{y})^2-2\mathbf{xy}\right]^2-2\mathbf{x}^2\mathbf{y}^2+(\mathbf{x}+\mathbf{y})^4\\&=(25-2)^2-2+5^4\\&=529-2+625\\&=1152\end{aligned}$$

ដូចនេះ $\mathbf{S}=1152$ ។

## លំហាត់ទី៨

គណនាតម្លៃនៃកន្សោម :

$$P=(\sqrt{10}+\sqrt{11}+\sqrt{12})(\sqrt{10}+\sqrt{11}-\sqrt{12})(\sqrt{10}-\sqrt{11}+\sqrt{12})(\sqrt{10}-\sqrt{11}-\sqrt{12})$$

## ដំណោះស្រាយ

គណនាតម្លៃនៃ **P**

គេមាន $M=(\sqrt{10}+\sqrt{11}+\sqrt{12})(\sqrt{10}+\sqrt{11}-\sqrt{12})$

$$=(\sqrt{10}+\sqrt{11})^2-(\sqrt{12})^2$$

$$=10+2\sqrt{110}+11-12$$

$$=9+2\sqrt{110}$$

និង $N=(\sqrt{10}-\sqrt{11}+\sqrt{12})(\sqrt{10}-\sqrt{11}-\sqrt{12})$

$$=(\sqrt{10}-\sqrt{11})^2-(\sqrt{12})^2$$

$$=10-2\sqrt{110}+11-12$$

$$=9-2\sqrt{110}$$

គេបាន $P=M.N=(9+2\sqrt{110})(9-2\sqrt{110})$

$$=81-440=-359$$

ដូចនេះ $P=-359$ ។

## លំហាត់ទី៩

គណនា $N=\dfrac{\sqrt{15}+\sqrt{35}+\sqrt{21}+5}{\sqrt{3}+2\sqrt{5}+\sqrt{7}}$

## ដំណោះស្រាយ

គណនា $N=\dfrac{\sqrt{15}+\sqrt{35}+\sqrt{21}+5}{\sqrt{3}+2\sqrt{5}+\sqrt{7}}$

គេមាន $N=\dfrac{(\sqrt{15}+\sqrt{21})+(\sqrt{35}+5)}{(\sqrt{3}+\sqrt{5})+(\sqrt{5}+\sqrt{7})}=\dfrac{(\sqrt{3}+\sqrt{5})(\sqrt{5}+\sqrt{7})}{(\sqrt{3}+\sqrt{5})+(\sqrt{5}+\sqrt{7})}$

គេបាន $\dfrac{1}{N}=\dfrac{(\sqrt{3}+\sqrt{5})+(\sqrt{5}+\sqrt{7})}{(\sqrt{3}+\sqrt{5})(\sqrt{5}+\sqrt{7})}=\dfrac{1}{\sqrt{5}+\sqrt{7}}+\dfrac{1}{\sqrt{3}+\sqrt{5}}$

$$=\frac{\sqrt{7}-\sqrt{5}}{2}+\frac{\sqrt{5}-\sqrt{3}}{2}=\frac{\sqrt{7}-\sqrt{3}}{2}=\frac{2}{\sqrt{7}+\sqrt{3}}$$

ដូចនេះ $N=\dfrac{\sqrt{7}+\sqrt{3}}{2}$ ។

## លំហាត់ទី១០

សម្រួល $A=\sqrt{2+\sqrt{-2+2\sqrt{5}}}-\sqrt{2-\sqrt{-2+2\sqrt{5}}}$

## ដំណោះស្រាយ

សម្រួល $A=\sqrt{2+\sqrt{-2+2\sqrt{5}}}-\sqrt{2-\sqrt{-2+2\sqrt{5}}}$

តាង $a=\sqrt{2+\sqrt{-2+2\sqrt{5}}}$ និង $b=\sqrt{2-\sqrt{-2+2\sqrt{5}}}$

គេបាន $a^2+b^2=4$ និង $ab=\sqrt{4-(-2+2\sqrt{5})}=\sqrt{6-2\sqrt{5}}=\sqrt{5}-1$

គេមាន $(a-b)^2=a^2+b^2-2ab=4-2\sqrt{5}+2=(\sqrt{5}-1)^2$

គេទាញបាន $a-b=\sqrt{5}-1$

ដូចនេះ $A=a-b=\sqrt{5}-1$ ។

## លំហាត់ទី១១

គេដឹងថា $x=\sqrt{19-8\sqrt{3}}$ ។

គណនាតម្លៃ $A=\dfrac{x^4-6x^3-2x^2+18x+23}{x^2-8x+15}$

## ដំណោះស្រាយ

គណនាតម្លៃ $A=\dfrac{x^4-6x^3-2x^2+18x+23}{x^2-8x+15}$

គេមាន $x=\sqrt{19-8\sqrt{3}}=\sqrt{(4-\sqrt{3})^2}=4-\sqrt{3}$

នាំឱ្យ $(x-4)^2=3$ ឬ $x^2-8x+13=0$

កន្សោម A អាចសរសេរមួយបែបទៀតគឺ :

$A=\dfrac{(x^2-18x+13)(x+1)^2+10}{(x^2-8x+13)+2}$ ដោយ $x^2-8x+13=0$

ដូចនេះ $A=\dfrac{10}{2}=5$ ។

## លំហាត់ទី១២

សម្រួល $y=\sqrt[3]{a+\frac{a+8}{3}\sqrt{\frac{a-1}{3}}}+\sqrt[3]{a-\frac{a+8}{3}\sqrt{\frac{a-1}{3}}}$ ដែល $a\geq 1$ ។

## ដំណោះស្រាយ

សម្រួល $y=\sqrt[3]{a+\frac{a+8}{3}\sqrt{\frac{a-1}{3}}}+\sqrt[3]{a-\frac{a+8}{3}\sqrt{\frac{a-1}{3}}}$

យក $x=\sqrt{\frac{a-1}{3}}$ នាំឱ្យ $a=3x^2+1$ និង $\frac{a+8}{3}=x^2+3$

កន្សោមខាងដើមអាចសរសេរជា :

$$y=\sqrt[3]{3x^2+1+x(x^2+3)}+\sqrt[3]{3x^2+1-x(x^2+3)}$$
$$=\sqrt[3]{x^3+3x^2+3x+1}+\sqrt[3]{1-3x+3x^2-x^3}$$
$$=\sqrt[3]{(x+1)^3}+\sqrt[3]{(1-x)^3}$$
$$=x+1+1-x=2$$

ដូចនេះ $y=2$ ។

## លំហាត់ទី១៣

គេឱ្យចំនួន $A=21a78_{10}$ និង $B=87b12_{10}$ ដែល a និង b ជាលេខ ។

បើ $A\times 4=B$ នោះចូរកំណត់គ្រប់គូ $(a,b)$ ?

## ដំណោះស្រាយ

កំណត់គ្រប់គូ $(a,b)$

គេមាន $A=21a78_{10}=2\times 10^4+1\times 10^3+a\times 10^2+7\times 10+8$

$A=21078+100a$

ហើយ $B=87b12_{10}=8\times 10^4+7\times 10^3+b\times 10^2+1\times 10+2$

$B=87012+100b$

ដោយ $A\times 4=B$ នោះ $4(21078+100a)=87012+100b$

ឬ $84312+400a=87012+100b$

$400a-100b=87012-84312$

$100(4a-b)=2700$

$4a-b=27$

គេទាញ $a=\dfrac{27+b}{4}$

ដោយ b ជាលេខនោះ $b=\{0, 1, 2, 3, 4, 5, 6, 7, 8, 9\}$

ហើយដោយ a ជាលេខដែរនោះតម្លៃដែលអាចរបស់ b គឺ $\{1, 5, 9\}$

ដូចនេះ $(a,b)=\{(7,1),(8,5),(9,9)\}$ ។

## លំហាត់ទី១៤

គេឱ្យ $a , b , c$ ជាលេខ ។

គេតាង $x = ab_{10}$ , $y = x - 10$ និង $z = ccc_{10}$

គេដឹងថា $x.y = z$ ។ ចូរកំណត់គូ $(a, b, c)$

## ដំណោះស្រាយ

កំណត់គូ $(a, b, c)$

គេមាន $x = ab_{10} = 10a + b$ , $y = x - 10 = 10a + b - 10$

និង $z = ccc_{10} = c \times 10^2 + c \times 10 + c = 111\,c$

ដោយ $xy = z$ នោះ $x(x - 10) = 111c$

ឬ $x^2 - 10x - 111c = 0$ (E)

ឌីសគ្រីមីណង់បង្រួមនៃសមីការ $\Delta' = 25 + 111c$

ដោយ $x$ ជាចំនួនគត់វិជ្ជមាននោះ $\Delta'$ ជាការេប្រាកដ ។

គេមាន $c \neq 0$ និង $c = \{1 , 2 , 3 , 4 , 5 , 6 , 7 , 8 , 9\}$

គេទាញបាន $c = 9$ តែមួយគត់ដែលនាំឱ្យ $\Delta' = 1024 = (32)^2$ ជាការេប្រាកដ ។

ក្នុងករណីនេះគេបាន $x_1 = 5 + 32 = 37$ ; $x_2 = 5 - 32 = -27$ ( មិនយក )

ដូចនេះ $x = 37$ តែ $x = 10a + b$ នោះគេទាញ $a = 3$ , $b = 7$ ។

ដូចនេះ $a = 3$ , $b = 7$ , $c = 9$ ។

ផ្ទៀងផ្ទាត់ $x = 37$ , $y = 27$ , $z = 999$ នោះ $37 \times 27 = 999$ ពិត ។

## លំហាត់ទី១៥

គេឱ្យចំនួន $\mathbf{n = \overline{aabb}_{10}}$ ដែល **a** និង **b** ជាលេខ ។

ក. ចូរបង្ហាញថាគ្រប់លេខ **a** និង **b** ចំនួន **n** ចែកដាច់នឹង **11** ជានិច្ច ។

ខ. គេយក $\mathbf{q = \frac{n}{11}}$ ។ បង្ហាញថាបើ **q** ចែកដាច់នឹង **11** នោះមានគូ$\mathbf{(a\ ,\ b)}$តែមួយគត់ដែល **n** ជាការេប្រាកដ ?

## ដំណោះស្រាយ

ក.បង្ហាញថាគ្រប់លេខ **a** និង **b** ចំនួន **n** ចែកដាច់នឹង **11** ជានិច្ច

គេមាន $\mathbf{n = \overline{aabb}_{10} = a\times 10^3 + a\times 10^2 + b\times 10 + b}$

$\mathbf{n = 1100a + 11b = 11(100a + b)}$ ជាពហុគុណនៃ **11** ។

ដូចនេះគ្រប់លេខ **a** និង **b** ចំនួន **n** ចែកដាច់នឹង **11** ជានិច្ច ។

ខ.កំណត់គូ $\mathbf{(a , b)}$

គេមាន $\mathbf{q = \frac{n}{11} = 100a + b = 99a + (a + b)}$

ចំនួន **q** ចែកដាច់នឹង **11** លុះត្រាតែ $\mathbf{a + b}$ ចែកដាច់នឹង **11** ។

ដោយ **a** និង **b** ជាលេខនោះ $\mathbf{0 < a + b \le 18}$ នាំឱ្យ $\mathbf{a + b = 11}$

គេបាន $\mathbf{q = 99a + 11 = 11(9a + 1)}$

គេទាញ $\mathbf{n = 11q = 11^2(9a + 1)}$ ។ ចំពោះ $\mathbf{a = 1\ ,\ 2\ ,\ 3, ..., 9}$ តម្លៃដែលធ្វើឱ្យ **n** ជាការេប្រាកដមានតែមួយគត់គឺ $\mathbf{a = 7}$ ដែលត្រូវនឹង $\mathbf{b = 11 - 7 = 4}$ ។

ដូចនេះ $\mathbf{a = 7\ ,\ b = 4}$ ហើយ $\mathbf{n = 7744 = 88^2}$ ។

## លំហាត់ទី១៦

គេឱ្យចំនួន $n = \overline{aaaaaa}_{10}$ ដែល $a = \{1,2,3,4,5,6,7,8,9\}$

ក. ចូរស្រាយថា $n$ ចែកដាច់នឹង $7$ ជានិច្ច ។

ខ. ចូរកំណត់គ្រប់លេខ $a$ ដើម្បីឱ្យ $n$ មានតួចែកយ៉ាងតិចមួយជាការេប្រាកដធំជាង $1$ ។

## ដំណោះស្រាយ

ក. ស្រាយថា $n$ ចែកដាច់នឹង $7$ ជានិច្ច

គេមាន $n = \overline{aaaaaa}_{10}$

$$= a\times10^5 + a\times10^4 + a\times10^3 + a\times10^2 + a\times10 + a$$

$$= (10^5 + 10^4 + 10^3 + 10^2 + 10 + 1)\times a$$

$$= 111111\times a$$

$$= 15873\times7\times a$$

ដូចនេះ $n$ ចែកដាច់នឹង $7$ ជានិច្ច ។

ខ. កំណត់គ្រប់លេខ $a$ ដើម្បីឱ្យ $n$ មានតួចែកជាការេប្រាកដ :

គេមាន $111111 = 3\times7\times11\times13\times37$

គេបាន $n = 3\times7\times11\times13\times37\times a$ ដែល $a = \{1,2,3,4,5,6,7,8,9\}$

ដូចនេះដើម្បីឱ្យ $n$ មានតួចែកយ៉ាងតិចមួយដែលជាការេប្រាកដលុះត្រាតែ

$a = 3 , 4 , 6 , 7 , 8 , 9$ ។

## លំហាត់ទី១៧

គេឱ្យចំនួន $\mathbf{n = \overline{aaabbb}_{10}}$ ដែល $\mathbf{a \neq b}$ និង $\mathbf{a , b}$ ជាលេខ ។

ក.ចូរសរសេរ **n** ជាទម្រង់ពន្លាត រួចបង្រួម ។

ខ. កំណត់គ្រប់គូ **(a , b )** ដែលធ្វើឱ្យ **n** ចែកដាច់នឹង 7 ។

## ដំណោះស្រាយ

ក.សរសេរ **n** ជាទម្រង់ពន្លាត រួចបង្រួម

គេមាន $\mathbf{n = \overline{aaabbb}_{10}}$

$$= a\times10^5 + a\times10^4 + a\times10^3 + b\times10^2 + b\times10 + b$$

$$= a\times10^3(10^2 + 10 + 1) + b(10^2 + 10 + 1)$$

$$= 111(1000a + b)$$

ខ.កំណត់គ្រប់គូ **(a , b )** ដែលធ្វើឱ្យ **n** ចែកដាច់នឹង 7

គេអាចសរសេរ :

$$n = 111(1000a + b)$$

$$= 3\times37\times(1000a + b)$$

$$= 3\times37\times[142\times7a + (6a + b)]$$

ដើម្បីឱ្យ **n** ចែកដាច់នឹង 7 លុះត្រាតែ $\mathbf{6a + b}$ ចែកដាច់នឹង 7 ។

ដោយ $\mathbf{a \neq b}$ និង $\mathbf{a \neq 0}$ ដូចនេះដើម្បីឱ្យ $\mathbf{6a + b}$ ចែកដាច់នឹង 7 លុះត្រាតែ :

$\mathbf{(a,b) \in \{(1,8),(2,9),(7,0),(8,1),(9,2)\}}$ ។

## លំហាត់ទី១៨

គេឱ្យចំនួន $n = \overline{abcd}_2$ ក្នុងប្រព័ន្ធរាប់គោល 2 ដែល $a , b , c , d \in \{0,1\}$ ។

ក. ចូរសរសេរ $n$ ជាទម្រង់ពន្លាត ។

ខ. បើ $a = b = c = 1$ នោះចូរកំណត់ $d$ ដើម្បីឱ្យ $n$ ចែកដាច់នឹង 5 ។

គ. បើ $a = b = d = 1$ នោះចូរកំណត់ $c$ ដើម្បីឱ្យ $n$ ចែកដាច់នឹង 3 ។

ឃ. បើ $a = c = d = 1$ នោះចូរកំណត់ $b$ ដើម្បីឱ្យ $n$ ចែកដាច់នឹង 11 ។

## ដំណោះស្រាយ

ក. សរសេរ $n$ ជាទម្រង់ពន្លាត

គេបាន $n = \overline{abcd}_2 = a\times 2^3 + b\times 2^2 + c\times 2 + d$

ខ. កំណត់ $d$ ដើម្បីឱ្យ $n$ ចែកដាច់នឹង 5

បើ $a = b = c = 1$ នោះ $n = 2^3 + 2^2 + 2 + d = 14 + d$

ដូចនេះដើម្បីឱ្យ $n$ ចែកដាច់នឹង 5 គឺមានតែ $d = 1$ ។

គ. កំណត់ $c$ ដើម្បីឱ្យ $n$ ចែកដាច់នឹង 3

បើ $a = b = d = 1$ នោះ $n = 2^3 + 2^2 + 2c + 1 = 13 + 2c$

ដូចនេះ ដើម្បីឱ្យ $n$ ចែកដាច់នឹង 3 គឺមានតែ $c = 1$ ។

ឃ. កំណត់ $b$ ដើម្បីឱ្យ $n$ ចែកដាច់នឹង 11

បើ $a = c = d = 1$ នោះ $n = 2^3 + 4b + 2 + 1 = 11 + 4b$

ដូចនេះ ដើម្បីឱ្យ $n$ ចែកដាច់នឹង 11 គឺមានតែ $b = 0$ ។

## លំហាត់ទី១៩

គេឱ្យចំនួន $n = 1100101_2$ ( ក្នុងប្រព័ន្ធគោល 2 )

និងចំនួន $p = 14285b_{10}$ ( ក្នុងប្រព័ន្ធគោល 10 )

ក.ចូរសរសេរ $n$ ទៅជាចំនួនក្នុងប្រព័ន្ធគោល 10 ។

ខ.កំណត់លេខ $b$ ដើម្បីឱ្យ $\dfrac{p \times b + 1}{9(n+6)+10}$ ជាចំនួនគត់ ?

## ដំណោះស្រាយ

ក.សរសេរ $n$ ទៅជាចំនួនក្នុងប្រព័ន្ធគោល 10

គេបាន $n = 1100101_2$

$$= 1 \times 2^6 + 1 \times 2^5 + 1 \times 2^2 + 1 = 104$$

ដូចនេះ $n = 104$

ខ.កំណត់លេខ $b$ ដើម្បីឱ្យ $\dfrac{p \times b + 1}{9(n+6)+10}$ ជាចំនួនគត់

គេមាន $9(n+6)+10 = 990 + 10 = 1000$

ហើយ $p = 14285b_{10} = 142850 + b$ នាំឱ្យ $p \times b + 1 = (142850 + b)b + 1$

ដើម្បីឱ្យ $\dfrac{p \times b + 1}{9(n+6)+10}$ ជាចំនួនគត់លុះត្រាតែ $(142850 + b)b + 1$ ចែកដាច់នឹង 1000

ដោយ $b$ ជាលេខនោះគេបាន $b = 7$ តែមួយគត់ព្រោះចំពោះ $b = 7$ គេបាន :

$(142850 + b)b + 1 = 142857 \times 7 + 1 = 1000000$ ចែកដាច់នឹង 1000 ។

ដូចនេះ $b = 7$ ជាចម្លើយដែលត្រូវរក ។

## លំហាត់ទី២០

គេឱ្យចំនួន $m = \overline{21a7b}_{10}$ និង $n = \overline{b7a12}_{10}$

ចូរកំណត់លេខ **a** និង **b** ដើម្បីឱ្យ $\frac{n}{m} = 4$ ?

## ដំណោះស្រាយ

កំណត់លេខ **a** និង **b**

គេមាន $m = \overline{21a7b}_{10}$

$$= 20000 + 1000 + 100a + 70 + b$$

$$= 21070 + 100a + b$$

និង $n = \overline{b7a12}_{10}$

$$= 10000b + 7000 + 100a + 10 + 2$$

$$= 10000b + 100a + 7012$$

ដោយ $\frac{n}{m} = 4$ នោះ $n = 4m$

$$10000b + 100a + 7012 = 4(20170 + 100a + b)$$

$$9996b - 3000a = 73668$$

$$3332b - 1000a = 24556$$

គេទាញ $a = \frac{3332b - 24556}{1000}$

ដោយ $a \geq$ នោះ $b \geq \frac{25556}{3332}$ ឬ $b \geq 8$ ហេតុនេះ $b = 8$ ឬ $b = 9$ ។

ចំពោះ $b = 8$ នោះ $a = 2$ ហើយចំពោះ $b = 9$ នោះ $a \in IN$

ដូចនេះ $a = 2 , b = 9$ ។

*មេរៀនសង្ខេប*

# ពហុធា និង វិធីចែកពហុធា

## ១_ឯកធា និង ពហុធា

***ក_ឯកធា***

-ឯកធា គឺជាកន្សោមដែលរបមាណវិធីលើអថេរមានតែវិធីគុណ និង ស្វ័យគុណដែលមាន និទស្សន្តគត់វិជ្ជមាន ឬ សូន្យ ។

-ឯកធាដូចគ្នា គឺជាឯកធាដែលមានផ្នែកអថេរដូចគ្នា ។

-ដឺក្រេនៃឯកធា ជាផលបូកនិទស្សន្តរបស់អថេរនីមួយៗនៃឯកធា ។

***ខ_ពហុធា***

-ពហុធា ជាផលបូកនៃច្រើនឯកធាខុសគ្នា ។

-ដឺក្រេនៃពហុធា គឺជាដឺក្រេរបស់តួដែរមានដឺក្រេខ្ពស់ជាងគេ ។

***គ_ប្រមាណវិធីលើពហុធា***

-ដើម្បីធ្វើ ផលបូក ឬ ដក នៃពហុធា ពីរ ឬច្រើន គេត្រូវបូក ឬ ដកឯកធាដែលដូចគ្នា ។

-ដើម្បីគុណពហុធា និង ពហុធា គេយកតួនីមួយៗនៃពហុធាទីមួយ គុណគ្រប់តួនៃពហុធាទីពីរ រួចធ្វើប្រមាណវិធី ( បង្រួម ) ។

*ឃ-រូបមន្ត*

1. $(a+b)^2 = a^2 + 2ab + b^2$
2. $(a-b)^2 = a^2 - 2ab + b^2$
3. $(a+b)^3 = a^3 + 3a^2b + 3ab^2 + b^3$
4. $(a-b)^3 = a^3 - 3a^2b + 3ab^2 - b^3$
5. $(a-b)(a+b) = a^2 - b^2$
6. $(a+b+c)^2 = a^2 + b^2 + c^2 + 2ab + 2bc + 2ca$
7. $(a+b)(a^2 - ab + b^2) = a^3 + b^3$
8. $(a-b)(a^2 + ab + b^2) = a^3 - b^3$
9. $acx^2 + (ad+bc)x + bd = (ax+b)(cx+d)$

## ២-ប្រមាណវិធីចែកពហុធា

### *ក-ទ្រឹស្តីវិធីចែកពហុធា*

-ឧបមាថាគេមានពហុធាពីរ **A** និង **B** មានអថេរដូចគ្នា ហើយមានដឺក្រេ **m** និង **n** រៀងគ្នា ។ បើ $m \geq n$ គេអាចរកកន្សោមពីជគណិត **Q** និង **R** ដែលផ្ទៀងផ្ទាត់ $A = B \times Q + R$ ។ ដឺក្រេនៃ **R** តូចជាងដឺក្រេនៃ **B** ។

**Q** ជាផលចែក ហើយ **R** ជាសំណល់នៅក្នុងវិធីចែក ។ ផលចែក **Q** មានដឺក្រេ $m-n$ ។

-បើ $R = 0$ គេបាន $A = B \times Q$ នោះគេថា **A** ចែកដាច់នឹង **B** ។

## ខ_តួចែករួមធំបំផុត និង ពហុគុណរួមតូចបំផុត

-តួចែករួមធំបំផុតនៃកន្សោម A និងB គឺជាផលគុណកត្តារួមដែលមាននិទស្សន្តតូចជាងគេ

-ពហុគុណរួមតូចបំផុត គឺជាផលគុណគ្រប់កត្តាមិនរួម និង គ្រប់កត្តារួមដែលមាននិទស្សន្ត ធំជាងគេ ។

### ✱ វិធាន

♦ដើម្បីគណនាតួចែករួមធំបំផុត :

1. ដាក់ជាផលគុណកត្តាគ្រប់តួទាំងអស់ ។
2. ជ្រើសរើសយកតែកត្តារួម ដែលមាននិទស្សន្តតូចជាងគេ ។
3. តួចែករួមធំបំផុតជាផលគុណកត្តារួមទាំងនោះ ។

♦ដើម្បីគណនាតួចែករួមតូចបំផុត :

1. ដាក់ជាផលគុណកត្តាគ្រប់តួទាំងអស់ ។
2. ជ្រើសរើសយកកត្តាមិនរួម និង កត្តាដែលមាននិទស្សន្តធំជាងគេ ។
3. ពហុគុណរួមតូចបំផុតជាផលគុណកត្តាទាំងនោះ ។

## គ_ប្រមាណវិធីបូក ដកកន្សោមប្រភាគ

1. $\frac{A}{D}+\frac{B}{D}=\frac{A+B}{D}$
2. $\frac{A}{D}-\frac{B}{D}=\frac{A-B}{D}$
3. $\frac{A}{D}+\frac{B}{D}-\frac{C}{D}=\frac{A+B-C}{D}$ ( $D\neq 0$ )

**✱ *វិធាន***

♦ដើម្បីគណនាផលបូក ឬ ដកប្រភាគ :

1. តម្រូវប្រភាគនីមួយៗឱ្យមានភាគបែងរួម ។

2. ធ្វើប្រមាណវិធី បូក ឬ ដកភាគយក ទុកភាគបែងរួម ។

3. សម្រួលលទ្ធផល ។

***ឃ_ប្រមាណវិធីគុណ និង ប្រមាណវិធីចែក***

1. $\frac{A}{B}\times\frac{C}{D}=\frac{A\times C}{B\times D}$

2. $\frac{A}{B}\div\frac{C}{D}=\frac{A}{B}\times\frac{D}{C}=\frac{A\times D}{B\times C}$

( $B , C , D \neq 0$ )

**✱ *វិធាន***

♦ដើម្បីគណនាផលគុណ និង ផលចែកប្រភាគ :

1. ដាក់ភាគយក និង ភាគបែងជាផលគុណកត្តា ។

2. សម្រួលកន្សោមប្រភាគនីមួយៗ ។

3. ធ្វើប្រមាណវិធីគុណ ឬ ចែកតាមរូបមន្តគ្រឹះ ។

# កម្រងលំហាត់ជ្រើសរើស

1. គណនាកន្សោម :

$$E = \frac{9x^2 - 6x + 1}{5 - x} \times \frac{5(x-2) - x(x-2)}{x^2 - 4x + 4} \times \frac{1}{3x - 1}$$

កំណត់គ្រប់ចំនួនគត់ $x$ ដើម្បីឱ្យ $E$ ជាចំនួនគត់ ។

2. គេឱ្យពហុធា $A(x) = x^3 + ax^2 + bx + c$ ដែល $a , b , c \in Z$

ចូរកំណត់ $a , b , c$ ដើម្បីឱ្យ $x = \sqrt{1 + \sqrt[3]{4} + \sqrt[3]{16}}$ ជាឬសរបស់ $A(x) = 0$ ។

3. ចូរបង្ហាញថា $(a^2 + b^2)(x^2 + y^2) = (ax - by)^2 + (bx + ay)^2$

រួចទាញថា $|bx + ay| \le \sqrt{a^2 + b^2} . \sqrt{x^2 + y^2}$ គ្រប់ចំនួនពិត $a , b , x, y$ ។

4. គេឱ្យ $x = \frac{a - b}{a + b}$ , $y = \frac{b - c}{b + c}$ , $z = \frac{c - a}{c + a}$

ចូរបង្ហាញថា $(1 + x)(1 + y)(1 + z) = (1 - x)(1 - y)(1 - z)$

5. គេឱ្យពហុធា $f(x) = x^3 - 6x^2 + 9x + \lambda$

ក. កំណត់ចំនួនពិត $\lambda$ ដើម្បីឱ្យ $f(x)$ ចែកដាច់នឹង $x - 4$ ។

ខ. ចំពោះតម្លៃ $\lambda$ ដែលបានរកឃើញ ចូរដាក់ $f(x)$ ជាផលគុណកត្តា ។

គ. ចូររក $x$ ជាចំនួនគត់វិជ្ជមានដើម្បីឱ្យ $f(x)$ ជាការេប្រាកដ ។

6. គេឱ្យពហុធា $f(x) = x^3 + px + q$

ក. កំណត់ $p$ និង $q$ ដើម្បីឱ្យ $f(x)$ ចែកដាច់នឹង $x^2 - 2x + 1$

ខ. ចំពោះតម្លៃ $p$ និង $q$ ដែលបានរកឃើញខាងលើ ចូរកំនត់គ្រប់ចំនួនគត់វិជ្ជមាន $x$

ដែលនាំឱ្យ $f(x)$ ជាការេប្រាកដ ។

7. គេឱ្យពហុធា $P(x)=2(x^2-3x+1)^7$

រកសំណល់នៃវិធីចែករវាង $P(x)$ នឹង $x^2-4x+3$ ។

8. គេមានពហុធា $P(x)=ax^3+bx^2+cx+d$

គេដឹងថា $P(x)$ ចែកនឹង $x$ ឱ្យសំណល់ $2$ ហើយ $P(x)$ ចែកនឹង $x+1$ ឱ្យសំណល់ $1$

ក. តើ $P(x)$ ចែកនឹង $x^2+x$ ឱ្យសំណល់ប៉ុន្មាន ?

ខ. កំណត់ $a$ , $b$, $c$ , $d$ ដោយដឹងថា $P(1)=P(2)=10$ ។

9.គេឱ្យពហុធា $f(x)=ax^4+bx^3+cx^2+dx+e$

គេដឹងថា $f(k)=k$ គ្រប់ $k=1$ , $2$ , $3$ , $4$ និង $f(5)=77$ ។

ចូរកំនត់លេខមេគុណ $a$ , $b$ , $c$ , $d$ , $e$ ។

10. គេដឹងថា $\frac{a}{k+1}+\frac{b}{k+2}+\frac{c}{k+3}+\frac{d}{k+4}=\frac{1}{k}$ ចំពោះ $k=1$ , $2$ , $3$ , $4$ ។

ចូរគណនា $A=\frac{a}{6}+\frac{b}{7}+\frac{c}{8}+\frac{d}{9}$ ។

11. គេឱ្យពហុធា $A(x)=x^3+2x^2-38x+33$ និង $B(x)=x^2-6x+14$

ក. ចូរកំណត់ពីរចំនួនពិត $\alpha$ និង $\beta$ ដើម្បីឱ្យ

$A(x)=(\alpha x+\beta)(x^2-6x+4)+B(x)-5$ ចំពោះគ្រប់ចំនួនពិត $x$ ។

ខ. កំណត់តម្លៃ $\frac{A(x)}{B(x)}$ ចំពោះ $x=\sqrt{14+6\sqrt{5}}$ ។

12. គេឱ្យពហុធា $\mathbf{P(x)=x^4-4x^3+ax+b}$ ។

កំណត់ចំនួនពិត $\mathbf{a}$ និង $\mathbf{b}$ បើគេដឹងថា $\mathbf{P(x)}$ ចែកនឹង $\mathbf{x^2-4x+3}$ ឱ្យសំណល់ $\mathbf{4x-1}$ ។

## លំហាត់ទី១

គណនាកន្សោម :

$$E=\frac{9x^2-6x+1}{5-x}\times\frac{5(x-2)-x(x-2)}{x^2-4x+4}\times\frac{1}{3x-1}$$

កំណត់គ្រប់ចំនួនគត់ **x** ដើម្បីឱ្យ **E** ជាចំនួនគត់ ។

## ដំណោះស្រាយ

គណនាកន្សោម **E**

គេមាន $E=\frac{9x^2-6x+1}{5-x}\times\frac{5(x-2)-x(x-2)}{x^2-4x+4}\times\frac{1}{3x-1}$

$$=\frac{(3x-1)^2}{5-x}\times\frac{(x-2)(5-x)}{(x-2)^2}\times\frac{1}{3x-1}$$

$$=\frac{(3x-1)^2(x-2)(5-x)}{(5-x)(x-2)^2(3x-1)}=\frac{3x-1}{x-2}$$

ដូចនេះ $E=\frac{3x-1}{x-2}$ ដែល $x\neq\frac{1}{3}$ , $x\neq2$ , $x\neq5$ ។

កំណត់គ្រប់ចំនួនគត់ **x** :

គេមាន $E=\frac{3x-1}{x-2}=\frac{3(x-2)+5}{x-2}=3+\frac{5}{x-2}$

ដើម្បីឱ្យ **E** ជាចំនួនគត់លុះត្រាតែ $x-2$ ចែកដាច់ **5** ពោលគឺគេត្រូវឱ្យ $x=-3$ , $x=1$

$x=3$ , ឬ $x=7$ ។

ដូចនេះ $x\in\{-3,1,3,7\}$ ។

## លំហាត់ទី២

គេឱ្យពហុធា $\mathbf{A(x)=x^3+ax^2+bx+c}$ ដែល $\mathbf{a , b , c \in Z}$

ចូរកំណត់ $\mathbf{a , b , c}$ ដើម្បីឱ្យ $\mathbf{x=\sqrt{1+\sqrt[3]{4}+\sqrt[3]{16}}}$ ជាឫសរបស់ $\mathbf{A(x)=0}$ ។

## ដំណោះស្រាយ

កំណត់ $\mathbf{a , b , c}$

គេមាន $\mathbf{x=\sqrt{1+\sqrt[3]{4}+\sqrt[3]{16}}}$

$$\mathbf{x=\sqrt{1+\sqrt[3]{4}+2\sqrt[3]{2}}}$$

$$\mathbf{x=\sqrt{(1+\sqrt[3]{2})^2}}$$

$$\mathbf{x=1+\sqrt[3]{2}}$$

គេបាន $\mathbf{(x-1)^3=(\sqrt[3]{2})^3}$

នាំឱ្យ $\mathbf{x^3-3x^2+3x-3=0}$

ដូចនេះ $\mathbf{x=\sqrt{1+\sqrt[3]{4}+\sqrt[3]{16}}}$ ជាឫស $\mathbf{x^3-3x^2+3x-3=0}$ ។

ហេតុនេះ $\mathbf{x=\sqrt{1+\sqrt[3]{4}+\sqrt[3]{16}}}$ ជាឫសរបស់ $\mathbf{A(x)=x^3+ax^2+bx+c=0}$

លុះត្រាតែ $\mathbf{a=-3 , b=3 , c=-3}$ ។

ដូចនេះ $\mathbf{a=-3 , b=3 , c=-3}$ ជាចំនួនគត់ដែលត្រូវរក ។

## លំហាត់ទី៣

ចូរបង្ហាញថា $(a^2+b^2)(x^2+y^2)=(ax-by)^2+(bx+ay)^2$

រួចទាញថា $|bx+ay|\le\sqrt{a^2+b^2}.\sqrt{x^2+y^2}$ គ្រប់ចំនួនពិត $a$ , $b$ , $x$, $y$ ។

## ដំណោះស្រាយ

បង្ហាញថា $(a^2+b^2)(x^2+y^2)=(ax-by)^2+(bx+ay)^2$

តាង $A=(ax-by)^2+(bx+ay)^2$

$$=a^2x^2-2abxy+b^2y^2+b^2x^2+2abxy+a^2y^2$$

$$=a^2x^2+b^2y^2+b^2x^2+a^2y^2$$

$$=(a^2x^2+b^2x^2)+(a^2y^2+b^2y^2)$$

$$=x^2(a^2+b^2)+y^2(a^2+b^2)$$

$$=(a^2+b^2)(x^2+y^2)$$

ដូចនេះ $(a^2+b^2)(x^2+y^2)=(ax-by)^2+(bx+ay)^2$ ។

ទាញថា $|bx+ay|\le\sqrt{a^2+b^2}.\sqrt{x^2+y^2}$

ដោយ គ្រប់ចំនួនពិត $a$ , $b$ , $x$, $y$ គេមាន $(ax-by)^2\ge 0$

តាម $(a^2+b^2)(x^2+y^2)=(ax-by)^2+(bx+ay)^2$

គេទាញបាន $(a^2+b^2)(x^2+y^2)\ge(bx+ay)^2$

ដូចនេះ $|bx+ay|\le\sqrt{a^2+b^2}.\sqrt{x^2+y^2}$ ។

## លំហាត់ទី៤

គេឱ្យ $x=\frac{a-b}{a+b}$ , $y=\frac{b-c}{b+c}$ , $z=\frac{c-a}{c+a}$

ចូរបង្ហាញថា $(1+x)(1+y)(1+z)=(1-x)(1-y)(1-z)$

## ដំណោះស្រាយ

បង្ហាញថា $(1+x)(1+y)(1+z)=(1-x)(1-y)(1-z)$

គេមាន $1+x=1+\frac{a-b}{a+b}=\frac{2a}{a+b}$

$$1+y=1+\frac{b-c}{b+c}=\frac{2b}{b+c}$$

$$1+z=1+\frac{c-a}{c+a}=\frac{2c}{c+a}$$

គេបាន $(1+x)(1+y)(1+z)=\frac{8abc}{(a+b)(b+c)(c+a)}$ (1)

ហើយ $1-x=1-\frac{a-b}{a+b}=\frac{2b}{a+b}$

$$1-y=1-\frac{b-c}{b+c}=\frac{2c}{b+c}$$

$$1-z=1-\frac{c-a}{c+a}=\frac{2a}{c+a}$$

គេបាន $(1-x)(1-y)(-z)=\frac{8abc}{(a+b)(b+c)(c+a)}$ (2)

តាមទំនាក់ទំនង (1) និង (2) គេទាញបាន :

$(1+x)(1+y)(1+z)=(1-x)(1-y)(1-z)$ ពិត ។

## លំហាត់ទី៥

គេឱ្យពហុធា $f(x)=x^3-6x^2+9x+\lambda$

ក. កំណត់ចំនួនពិត $\lambda$ ដើម្បីឱ្យ $f(x)$ ចែកដាច់នឹង $x-4$ ។

ខ. ចំពោះតម្លៃ $\lambda$ ដែលបានរកឃើញ ចូរដាក់ $f(x)$ ជាផលគុណកត្តា ។

គ. ចូរក $x$ ជាចំនួនគត់វិជ្ជមានដើម្បីឱ្យ $f(x)$ ជាការេប្រាកដ ។

## ដំណោះស្រាយ

ក. កំណត់ចំនួនពិត $\lambda$

ដើម្បីឱ្យ $f(x)$ ចែកដាច់នឹង $x-4$ លុះត្រាតែមានកន្សោមពីជគណិត $Q(x)$ មួយដែល

$$f(x)=x^3-6x^2+9x+\lambda=(x-4)Q(x)$$

យក $x=4$ គេបាន $f(4)=64-96+36+\lambda=0$

គេទាញបាន $\lambda=-4$ ។

ខ. ដាក់ $f(x)$ ជាផលគុណកត្តា

ចំពោះ $\lambda=-4$ គេបាន $f(x)=x^3-6x^2+9x-4$

ដោយ $f(x)$ ចែកដាច់នឹង $x-4$ នោះគេអាចសរសេរ :

$$\begin{aligned}f(x)&=(x-4)(x^2+\alpha x+\beta)\\&=x^3+\alpha x^2+\beta x-4x^2-4\alpha x-4\beta\\&=x^3+(\alpha-4)x^2+(\beta-4\alpha)x-4\beta\end{aligned}$$

ដោយប្រៀបធៀបកន្សោមនេះជាមួយនឹង $f(x)=x^3-6x^2+9x-4$ គេបាន :

$$\begin{cases}\alpha-4=-6\\ \beta-4\alpha=9\\ -4\beta=-4\end{cases}$$ នាំឱ្យ $\alpha=-2$ , $\beta=1$

គេបាន $f(x)=(x-4)(x^2-2x+1)$

ដូចនេះ $f(x)=(x-4)(x-1)^2$ ។

គ.រក $x$ ជាចំនួនគត់វិជ្ជមានដើម្បីឱ្យ $f(x)$ ជាការេប្រាកដ

គេមាន $f(x)=(x-4)(x-1)^2$

ដោយ $(x-1)^2$ ជាការេប្រាកដគ្រប់ចំនួនគត់វិជ្ជមាន $x>1$ នោះដើម្បីឱ្យ $f(x)$ ជាការេប្រាកដនោះគេគ្រាន់តែឱ្យ $x-4$ ជាការេប្រាកដ ។

គេបាន $x-4=p^2$ គ្រប់ $p\in IN=\{1,2,3,...\}$

ដូចនេះ $x=p^2+4$ ។

## លំហាត់ទី៦

គេឱ្យពហុធា $f(x) = x^3 + px + q$

ក. កំណត់ $p$ និង $q$ ដើម្បីឱ្យ $f(x)$ ចែកដាច់នឹង $x^2 - 2x + 1$

ខ. ចំពោះតម្លៃ $p$ និង $q$ ដែលបានរកឃើញខាងលើ ចូរកំនត់គ្រប់ចំនួនគត់វិជ្ជមាន $x$ ដែលនាំឱ្យ $f(x)$ ជាការេប្រាកដ ។

## ដំណោះស្រាយ

ក. កំណត់ $p$ និង $q$

ដើម្បីឱ្យ $f(x)$ ចែកដាច់នឹង $x^2 - 2x + 1 = (x-1)^2$ លុះត្រាតែមានកន្សោមពីជគណិត $Q(x)$ មួយដែល $f(x) = (x-1)^2 Q(x)$

ឬ $x^3 + px + q = (x-1)^2 Q(x)$ (1)

យក $x = 1$ ជួសក្នុង (1) គេបាន : $1 + p + q = 0 \Rightarrow q = -1 - p$

គេបាន $f(x) = x^3 + px - 1 - p$

$$= (x-1)(x^2 + x + 1) + p(x-1)$$

$$= (x-1)(x^2 + x + 1 + p)$$

ដោយ $f(x)$ ចែកដាច់នឹង $(x-1)^2$ នោះគេបាន $x^2 + x + 1 + p$ ត្រូវតែចែកដាច់នឹង $x - 1$ ពោលគឺ $x = 1$ ជាឫស $x^2 + x + 1 + p = 0$

គេបាន $1^2 + 1 + 1 + p = 0 \Rightarrow p = -3$ ហើយ $q = -1 - (-3) = 2$

ដូចនេះ $p = -3$ , $q = 2$ ។

ខ. កំនត់គ្រប់ចំនួនគត់វិជ្ជមាន $\mathbf{x}$

ចំពោះ $\mathbf{p=-3}$ , $\mathbf{q=2}$

គេបាន $\mathbf{f(x)=x^3-3x+2=(x-1)^2(x+\alpha)}$

យក $\mathbf{x=0}$ គេបាន $\mathbf{f(0)=2=\alpha}$

ដូចនេះ $\mathbf{f(x)=(x-1)^2(x+2)}$

ដោយកត្តា $\mathbf{(x-1)^2}$ ជាការេប្រាកដគ្រប់ចំនួនគត់ $\mathbf{x>1}$ ។

ហេតុនេះដើម្បីឱ្យ $\mathbf{f(x)}$ ជាការេប្រាកដលុះត្រាតែ $\mathbf{x+2}$ ជាការេប្រាកដ ។

គេបាន $\mathbf{x+2=k^2}$ $\mathbf{\forall k\geq 2}$ , $\mathbf{k\in IN}$

ដូចនេះ $\mathbf{x=k^2-2}$ ។

## លំហាត់ទី៧

គេឱ្យពហុធា $P(x) = 2(x^2 - 3x + 1)^7$

រកសំណល់នៃវិធីចែករវាង $P(x)$ នឹង $x^2 - 4x + 3$ ។

## ដំណោះស្រាយ

រកសំណល់

តាង $R(x) = ax + b$ ជាសំណល់នៃវិធីចែករវាង $P(x)$ នឹង $x^2 - 4x + 3$ នោះមាន

កន្សោមពីជគណិត $Q(x)$ ដែល $P(x) = (x^2 - 4x + 3)Q(x) + R(x)$

ឬ $2(x^2 - 3x + 1)^7 = (x^2 - 4x + 3)Q(x) + ax + b$

យើងដឹងថា $x^2 - 4x + 3 = 0$ ពេលដែល $x = 1$ ឬ $x = 3$

បើ $x = 1$ គេបាន $-2 = a + b$ (1)

បើ $x = 3$ គេបាន $2 = 3a + b$ (2)

យកសមីការ (2) ដកសមីការ (1) គេបាន $4 = 2a \Rightarrow a = 2$

តាម (1) គេបាន $b = -2 - a = -2 - 2 = -4$

ដូចនេះ $a = 2$ , $b = -4$ និង $R(x) = -2x + 4$ ។

## លំហាត់ទី៨

គេមានពហុធា $\mathbf{P(x)=ax^3+bx^2+cx+d}$

គេដឹងថា $\mathbf{P(x)}$ ចែកនឹង $\mathbf{x}$ ឱ្យសំណល់ $\mathbf{2}$ ហើយ $\mathbf{P(x)}$ ចែកនឹង $\mathbf{x+1}$ ឱ្យសំណល់ $\mathbf{1}$

ក. តើ $\mathbf{P(x)}$ ចែកនឹង $\mathbf{x^2+x}$ ឱ្យសំណល់ប៉ុន្មាន ?

ខ. កំណត់ $\mathbf{a\ ,\ b,\ c\ ,\ d}$ ដោយដឹងថា $\mathbf{P(1)=P(2)=10}$ ។

## ដំណោះស្រាយ

ក. តើ $\mathbf{P(x)}$ ចែកនឹង $\mathbf{x^2+x}$ ឱ្យសំណល់ប៉ុន្មាន ?

សម្មតិកម្ម $\mathbf{P(x)}$ ចែកនឹង $\mathbf{x}$ ឱ្យសំណល់ $\mathbf{2}$ ហើយ $\mathbf{P(x)}$ ចែកនឹង $\mathbf{x+1}$ ឱ្យសំណល់ $\mathbf{1}$

នាំឱ្យមានកន្សោមពីជគណិត $\mathbf{Q_1(x)}$ និង $\mathbf{Q_2(x)}$ ដែល :

$\mathbf{P(x)=xQ_1(x)+2}$ ឬ $\mathbf{\dfrac{P(x)}{x}=Q_1(x)+\dfrac{2}{x}}$ $\mathbf{(1)}$

$\mathbf{P(x)=(x+1)Q_2(x)+1}$ ឬ $\mathbf{\dfrac{P(x)}{x+1}=Q_2(x)+\dfrac{1}{x+1}}$ $\mathbf{(2)}$

ដកសមីការ $\mathbf{(1)}$ និង $\mathbf{(2)}$ គេបាន $\mathbf{\dfrac{P(x)}{x}-\dfrac{P(x)}{x+1}=Q_1(x)-Q_2(x)+\dfrac{2}{x}-\dfrac{1}{x+1}}$

ឬ $\mathbf{\dfrac{(x+1)-x}{x(x+1)}P(x)=Q_1(x)-Q_2(x)+\dfrac{x+2}{x(x+1)}}$

ឬ $\mathbf{P(x)=[Q_1(x)-Q_2(x)](x^2+x)+x+2}$

ទំនាក់ទំនងនេះបញ្ជាក់ថា $\mathbf{P(x)}$ ចែកនឹង $\mathbf{x^2+x}$ ឱ្យសំណល់ $\mathbf{R(x)=x+2}$ ។

ខ. កំណត់ **a , b, c , d**

តាមសម្រាយខាងលើ $P(x)$ ចែកនឹង $x^2+x$ ឱ្យសំណល់ $R(x)=x+2$ នាំឱ្យមាន

កន្សោមពីជគណិត $Q(x)=\alpha x+\beta$ ដែល $P(x)=(x^2+x)(\alpha x+\beta)+x+2$

ដោយដឹងថា $P(1)=P(2)=10$ នោះ $\begin{cases} 2(\alpha+\beta)+3=10 \\ 6(2\alpha+\beta)+4=10 \end{cases}$

ឬ $\begin{cases} \alpha+\beta=\dfrac{7}{2} \\ 2\alpha+\beta=1 \end{cases}$ នាំឱ្យ $\alpha=-\dfrac{5}{2}$ និង $\beta=6$

គេបាន $P(x)=(x^2+x)(-\dfrac{5x}{2}+6)+x+2$

$$P(x)=-\frac{5x^3}{2}+6x^2-\frac{5x^2}{2}+6x+x+2$$

$$P(x)=-\frac{5}{2}x^3+\frac{7}{2}x^2+7x+2$$

ដោយ $P(x)=ax^3+bx^2+cx+d$

ដូចនេះ $a=-\dfrac{5}{2}\ ,\ b=\dfrac{7}{2}\ ,\ c=7,\ d=2$ ។

## លំហាត់ទី៩

គេឱ្យពហុធា $f(x)=ax^4+bx^3+cx^2+dx+e$

គេដឹងថា $f(k)=k$ គ្រប់ $k=1\ ,\ 2\ ,\ 3\ ,\ 4$ និង $f(5)=77$ ។

ចូរកំនត់លេខមេគុណ $a\ ,\ b\ ,\ c\ ,\ d\ ,\ e$ ។

## ដំណោះស្រាយ

កំនត់លេខមេគុណ $a\ ,\ b\ ,\ c\ ,\ d\ ,\ e$

តាងពហុធា $g(x)=f(x)-x$ ដោយ $f(k)=k$ គ្រប់ $k=1\ ,\ 2\ ,\ 3\ ,\ 4$

នោះគេបាន $g(1)=g(2)=g(3)=g(4)=0$

ហេតុនេះ $g(x)=\lambda(x-1)(x-2)(x-3)(x-4)$

គេបាន $f(x)-x=\lambda(x-1)(x-2)(x-3)(x-4)$

ឬ $f(x)=\lambda(x-1)(x-2)(x-3)(x-4)+x$

បើ $x=5$ នោះ $f(5)=24\lambda+5$ តែ $f(5)=77$

គេបាន $24\lambda+5=77\Rightarrow\lambda=3$

ដូចនេះ $f(x)=3(x-1)(x-2)(x-3)(x-4)+x$

ឬ $f(x)=3x^4-30x^3+105x^2-149x+72$

ដោយ $f(x)=ax^4+bx^3+cx^2+dx+e$

ដូចនេះ $a=3\ ,\ b=-30\ ,\ c=105\ ,\ d=-149\ ,\ e=72$ ។

**លំហាត់ទី១០**

គេដឹងថា $\frac{a}{k+1}+\frac{b}{k+2}+\frac{c}{k+3}+\frac{d}{k+4}=\frac{1}{k}$ ចំពោះ $k=1\,,\,2\,,\,3\,,\,4$ ។

ចូរគណនា $A=\frac{a}{6}+\frac{b}{7}+\frac{c}{8}+\frac{d}{9}$ ។

**ដំណោះស្រាយ**

គណនា $A=\frac{a}{6}+\frac{b}{7}+\frac{c}{8}+\frac{d}{9}$

តាងពហុធា :

$$P(x)=x(x+1)(x+2)(x+3)(x+4)\left(\frac{a}{x+1}+\frac{b}{x+2}+\frac{c}{x+3}+\frac{d}{x+4}-\frac{1}{x}\right)\ \ (1)$$

គេមាន $\frac{a}{k+1}+\frac{b}{k+2}+\frac{c}{k+3}+\frac{d}{k+4}=\frac{1}{k}$ ចំពោះ $k=1\,,\,2\,,\,3\,,\,4$

ហេតុនេះ $P(1)=P(2)=P(3)=P(4)=0$ ។

ដោយ $P(x)$ ជាពហុធាដឺក្រេទីបួននៃ $x$ នោះនាំឱ្យមានចំនួនពិត $\lambda\neq 0$ ដែល

$$P(x)=\lambda(x-1)(x-2)(x-3)(x-4)\ \ (2)$$

តាម (1) គេអាចសរសេរ :

$$P(x)=x(x+1)...(x+4)\left(\frac{a}{x+1}+...+\frac{d}{x+4}\right)-(x+1)(x+2)(x+3)(x+4)$$

បើ $x=0\Rightarrow P(0)=-24$ តែតាម (2) $P(0)=24\lambda$

គេទាញបាន $24\lambda=-24\Rightarrow\lambda=-1$

ហេតុនេះ $P(x)=-(x-1)(x-2)(x-3)(x-4)\ (3)$

យក $\mathbf{x=5}$ ជួសក្នុង **(1)** គេបាន **:**

## ដំណោះស្រាយ

ស្រាយថា $\alpha^2+(p^3-3pq)\alpha+q^3=0$

បើ $x=\sqrt[3]{\alpha}$ ជាឬសរបស់សមីការ (E) នោះគេបាន $\sqrt[3]{\alpha^2}+p\sqrt[3]{\alpha}+q=0$ ។

តាមសមភាព

$a^3+b^3+c^3-3abc=(a+b+c)(a^2+b^2+c^2-ab-bc-ca)$

បើគេយក $a=\sqrt[3]{\alpha^2}$ , $b=p\sqrt[3]{\alpha}$ , $c=q$ គេបាន :

$\alpha^2+p^3\alpha+q^3-3\alpha pq=0$ ( ព្រោះ $\sqrt[3]{\alpha^2}+p\sqrt[3]{\alpha}+q=0$ )

ដូចនេះ $\alpha^2+(p^3-3pq)\alpha+q^3=0$ ពិត ។

## លំហាត់ទី១៤

ដោះស្រាយសមីការ

$$\frac{x^2-3x+2(1+\sqrt{3})}{\sqrt{6}+\sqrt{2}}=\sqrt{x^2-3x+2}$$

## ដំណោះស្រាយ

ដោះស្រាយសមីការ

$$\frac{x^2-3x+2(1+\sqrt{3})}{\sqrt{6}+\sqrt{2}}=\sqrt{x^2-3x+2}$$

សមីការមានន័យលុះត្រាតែ $x^2-3x+2\geq 0$

នាំឱ្យ $x\leq 1$ ឬ $x\geq 2$ ។

តាង $t=\sqrt{x^2-3x+2}$ សមីការអាចសរសេរ :

$$\frac{t^2+2\sqrt{3}}{\sqrt{6}+\sqrt{2}}=t \quad ឬ \quad t^2-(\sqrt{6}+\sqrt{2})t+2\sqrt{3}=0$$

$$\Delta=(\sqrt{6}+\sqrt{2})^2-8\sqrt{3}=(\sqrt{6}-\sqrt{2})^2$$

គេទាញឫស $t_1=\sqrt{2}$ , $t_2=\sqrt{6}$

-ចំពោះ $t=\sqrt{2}$ នោះ $\sqrt{x^2-3x+2}=\sqrt{2}$ ឬ $x^2-3x=0\Rightarrow x_1=0$ , $x_2=3$

-ចំពោះ $t=\sqrt{6}$ នោះ $\sqrt{x^2-3x+2}=\sqrt{6}$ ឬ $x^2-3x-4=0\Rightarrow x_1=-1$ , $x_2=4$

ដូចនេះ $x\in\{-1,0,3,4\}$ ។

**លំហាត់ទី១៥**

ដោះស្រាយសមីការ $x^2 - x + 6 = \sqrt{x^3 + 8}$

**ដំណោះស្រាយ**

ដោះស្រាយសមីការ

គេមាន $x^2 - x + 6 = \sqrt{x^3 + 8}$

$$x^2 - x + 6 = \sqrt{(x+2)(x^2 - 2x + 4)}$$

សមីការមានន័យលុះត្រាតែ $(x+2)(x^2 - 2x + 4) \geq 0$

ដោយ $x^2 - 2x + 4 > 0$ ជានិច្ចគ្រប់ $x \in IR$ ពោះ $a = 1 > 0$ , $\Delta = -12 < 0$

ហេតុនេះគេត្រូវឱ្យ $x + 2 \geq 0 \Rightarrow x \geq -2$ ។

តាង $u = x + 2$ , $v = x^2 - 2x + 4$

សមីការអាចសរសេរ $u + v \geq 2\sqrt{uv} \Leftrightarrow (\sqrt{u} - \sqrt{v})^2 = 0$ ឬ $u = v$

គេបាន $x + 2 = x^2 - 2x + 4$

ឬ $-x^2 + 3x - 2 = 0$ ដោយ $a + b + c = 0 \Rightarrow x_1 = 1$ , $x_2 = \frac{c}{a} = 2$

ដូចនេះ $x_1 = 1$ , $x_2 = 2$ ។

*មេរៀនសង្ខេប*

# អនុគមន៍ត្រីកោណមាត្រ និង ការអនុវត្តន៍

## ១_និយមន័យ

ក្នុងគ្រប់ត្រីកោណកែង **ABC** បើ **A** ជាមុំស្រួចមួយនោះគេមានទំនាក់ទំនងដូចខាងក្រោម :




$$\sin A = \frac{BC}{AB} \;;\; \cos A = \frac{AC}{AB}$$

$$\tan A = \frac{BC}{AC} \;;\; \cot A = \frac{AC}{BC}$$

## ២_ទំនាក់ទំនងរវាងផលធៀបត្រីកោណមាត្រ

$$\tan A = \frac{\sin A}{\cos A} \;;\; \cot A = \frac{\cos A}{\sin A}$$

$$\sin^2 A + \cos^2 A = 1 \;;\; \tan A = \frac{1}{\cot A}$$

$$1 + \tan^2 A = \frac{1}{\cos^2 A} \;;\; 1 + \cot^2 A = \frac{1}{\sin^2 A}$$

## ៣-តារាងតម្លៃផលធៀបត្រីកោណមាត្រនៃមុំពិសេស

| $\alpha$ | $0^o$ | $30^o$ | $45^o$ | $60^o$ | $90^o$ | $120^o$ | $135^o$ | $150^o$ | $180^o$ |
|---|---|---|---|---|---|---|---|---|---|
| $\sin\alpha$ | $0$ | $\frac{1}{2}$ | $\frac{\sqrt{2}}{2}$ | $\frac{\sqrt{3}}{2}$ | $1$ | $\frac{\sqrt{3}}{2}$ | $\frac{\sqrt{2}}{2}$ | $\frac{1}{2}$ | $0$ |
| $\cos\alpha$ | $1$ | $\frac{\sqrt{3}}{2}$ | $\frac{\sqrt{2}}{2}$ | $\frac{1}{2}$ | $0$ | $-\frac{1}{2}$ | $-\frac{\sqrt{2}}{2}$ | $-\frac{\sqrt{3}}{2}$ | $-1$ |
| $\tan\alpha$ | $0$ | $\frac{\sqrt{3}}{3}$ | $1$ | $\sqrt{3}$ | មិនកំណត់ | $-\sqrt{3}$ | $-1$ | $-\frac{\sqrt{3}}{3}$ | $0$ |

## ៤-ទ្រឹស្តីបទស៊ីនុស

គេឱ្យត្រីកោណ **ABC** មួយមានជ្រុង $\mathbf{BC = a}$ , $\mathbf{AC = b}$ , $\mathbf{AB = c}$ ចារឹកក្នុងរង្វង់មួយមានផ្ចិត **O** និងកាំ **R** ។




គេមានទំនាក់ទំនង $\frac{a}{\sin A} = \frac{b}{\sin B} = \frac{c}{\sin C} = 2R$ ។

## ៥_ទ្រឹស្តីបទកូស៊ីនូស

គេឱ្យត្រីកោណ **ABC** មួយមានជ្រុង $BC = a$ , $AC = b$ , $AB = c$




គេមានទំនាក់ទំនងដូចខាងក្រោម :

$$a^2 = b^2 + c^2 - 2bc\cos A$$

$$b^2 = c^2 + a^2 - 2ac\cos B$$

$$c^2 = a^2 + b^2 - 2ab\cos C$$

## ៦_ផ្ទៃក្រឡាត្រីកោណ

ក-ករណីស្គាល់ជ្រុងពីរ និង មុំមួយ

ផ្ទៃក្រឡា **S** នៃត្រីកោណ **ABC** មួយកំណត់ដោយ :

$$S = \frac{1}{2}bc\sin A = \frac{1}{2}ac\sin B = \frac{1}{2}ab\sin C$$

ខ-ករណីស្គាល់ជ្រុងទាំងបី ( រូបមន្តហេរ៉ុង )

ផ្ទៃក្រឡា **S** នៃត្រីកោណ **ABC** មួយកំណត់ដោយ :

$$S = \sqrt{p(p-a)(p-b)(p-c)}$$ ដែល $$p = \frac{a+b+c}{2}$$ ។

# កម្រងលំហាត់ជ្រើសរើស

1. គេមានត្រីកោណ $ABC$ មួយកែងត្រង់ $C$ ។ គេដឹងថា $AB = 10\text{ cm}$

និង $\sin A + \sin B = \dfrac{7}{5}$ ។

ចូរកំណត់ជ្រុង $AC$ និង $BC$ រួចទាញរក $\tan A$ និង $\tan B$ ។

2. ដោយដឹងថា $\tan\alpha = \dfrac{5}{12}$ និង $0^o < \alpha < 90^o$ ។

ចូរគណនាតម្លៃនៃ $\cos\alpha$ , $\sin\alpha$ និង $\cot\alpha$ ។

3. ចូរគណនា $A = \sqrt{\sin^4 x + 4\cos^2 x} + \sqrt{\cos^4 x + 4\sin^2 x}$

$$B = (a\sin x + b\cos x)^2 + (a\cos x - b\sin x)^2$$

4. គេដឹងថា $\tan x = \sqrt{\dfrac{b}{a}}$ ។

ចូរស្រាយថា $\dfrac{\cos^4 x}{a} + \dfrac{\sin^4 x}{b} = \dfrac{1}{a+b}$

5. គេដឹងថា $\sin x + \cos x = \dfrac{41}{29}$ ។

ចូរគណនាផលគុណ $\sin x.\cos x$ រួចទាញរក $\sin x$ និង $\cos x$ ។

6. គេដឹងថា $\tan x + \cot x = a$ ដែល $0 < x < 90^o$ និង $a \ge 2$ ។

ចូរគណនា $\tan^3 x + \cot^3 x$ ជាអនុគមន៍នៃ $a$ ។

7. ចំពោះគ្រប់ $x \in IR$ ចូរស្រាយបញ្ជាក់សមភាព :

ក. $\sin^6 x + \cos^6 x = 1 - 3\sin^2 x\cos^2 x$

ខ. $\frac{1}{4}(\sin^8 x+\cos^8 x)-\frac{1}{2}(\sin^4 x+\cos^4 x)+\frac{1}{4}=\frac{1}{2}\sin^4 x\cos^4 x$

8. គេដឹងថា $\cos a=\frac{m}{n+p}$ , $\cos b=\frac{n}{p+m}$ , $\cos c=\frac{p}{m+n}$

ចូរគណនាកន្សោម :

$$M=\frac{\sin^2 a}{2+2\cos a-\sin^2 a}+\frac{\sin^2 b}{2+2\cos b-\sin^2 b}+\frac{\sin^2 c}{2+2\cos c-\sin^2 c}$$

9.ចូរស្រាយបញ្ជាក់ថា $|a\cos x+b\sin x|\le\sqrt{a^2+b^2}$

10. គេមានត្រីកោណ $ABC$ មួយដែល $BC=a$ , $AC=b$ , $AB=c$ ។

ចូរស្រាយបញ្ជាក់សមភាព

$$bc\cos A+ac\cos B+ab\cos C=\frac{a^2+b^2+c^2}{2}$$

11. គេមានត្រីកោណ $ABC$ មួយដែល $BC=a$ , $AC=b$ , $AB=c$ ។

តាង $R$ និង $S$ រៀងគ្នាជាកាំ និង ផ្ទៃក្រឡានៃត្រីកោណ $ABC$ នេះ ។

ចូរស្រាយថា $\frac{\cos A}{a}+\frac{\cos B}{b}+\frac{\cos C}{c}=\frac{R(\sin^2 A+\sin^2 B+\sin^2 C)}{4S}$

12. ក្នុងគ្រប់ត្រីកោណ $ABC$ ចូរស្រាយថា :

$$(1+\cos A)(1+\cos B)(1+\cos C)=\frac{(\sin A+\sin B+\sin C)^2}{2}$$

13. ក្នុងគ្រប់ត្រីកោណចូរស្រាយថា :

$$(1-\cos A)(1-\cos B)(1-\cos C)=8\left(\frac{(p-a)(p-b)(p-c)}{abc}\right)^2$$

ដែល $a$ , $b$ , $c$ ជាជ្រុងត្រីកោណ $ABC$ និង $p=\frac{a+b+c}{2}$ ។

14. គេឱ្យត្រីកោណ $\mathbf{ABC}$ មួយ ។

ក. ចូរស្រាយបញ្ជាក់ថា $\mathbf{1-\cos A \le \dfrac{a^2}{2bc}}$

ដែល $\mathbf{a}$ , $\mathbf{b}$ , $\mathbf{c}$ ជាជ្រុងត្រីកោណ $\mathbf{ABC}$ ។

ខ. ទាញបញ្ជាក់ថា $\mathbf{(1-\cos A)(1-\cos B)(1-\cos C) \le \dfrac{1}{8}}$

15. គេឱ្យត្រីកោណ $\mathbf{ABC}$ មួយ ។

ក. ចូរស្រាយបញ្ជាក់ថា $\mathbf{\sin^2 A = \sin^2 B + \sin^2 C - 2\sin B \sin C \cos A}$

ខ. ទាញបញ្ជាក់ថា :

$$\mathbf{\cot A + \cot B + \cot C = \frac{\sin^2 A + \sin^2 B + \sin^2 C}{2\sin A \sin B \sin C}}$$

16. គេឱ្យត្រីកោណ $\mathbf{ABC}$ មួយមានមុំ $\mathbf{A,B,C}$ ជាមុំស្រួចដែលផ្ទៀងផ្ទាត់សមភាព

$$\mathbf{\cot A + \cot B + \cot C = \frac{1}{2}\left(\frac{1}{\sin A} + \frac{1}{\sin B} + \frac{1}{\sin C}\right)}$$ ។

ចូរស្រាយថា $\mathbf{ABC}$ ជាត្រីកោណសមង្ស័ ?

17. គេឱ្យត្រីកោណ $\mathbf{ABC}$ មួយមានជ្រុង $\mathbf{AB = 5\,cm}$ និងផ្ទៃក្រឡា $\mathbf{S = 6\,cm^2}$ ។

គណនាតម្លៃ $\mathbf{\cot A + \cot B}$ ។

18. តាង $\mathbf{R}$ ជាកាំរង្វង់ចារឹកក្នុង និង $\mathbf{S}$ ជាផ្ទៃក្រឡានៃត្រីកោណ $\mathbf{ABC}$ មួយ ។

ក. ចូរស្រាយថា $\mathbf{(\cot A + \cot B)(\cot B + \cot C)(\cot C + \cot A) = \dfrac{2R^2}{S}}$

ខ. បើ $\mathbf{ABC}$ ជាមុំស្រួចនោះចូរទាញឱ្យបានថា : $\mathbf{\cos A \cos B \cos C \le \dfrac{1}{8}}$ ។

19. គេឱ្យត្រីកោណ $ABC$ មួយមានជ្រុង $BC=a$ , $AC=b$ , $AB=c$ ចារឹកក្នុងរង្វង់មួយមានផ្ចិត $O$ និង កាំ $R$ ។ តាង $S$ និង $S_{OBC}$ ជាផ្ទៃក្រឡានៃ $\Delta OBC$ និង $\Delta ABC$ រៀងគ្នា ។ សន្មតថា $A,B,C$ ជាមុំស្រួច ។

ក. ចូរស្រាយថា $S_{OBC}=\frac{1}{4}a^2\cot A$ ។

ខ. ចូរទាញបង្ហាញថា $a^2\cot A+b^2\cot B+c^2\cot C=4S$ ។

គ. ចូរទាញបង្ហាញថា $a\cos A+b\cos B+c\cos C=\frac{abc}{2R^2}$ ។

20. គេឱ្យត្រីកោណ $ABC$ មួយមានជ្រុង $BC=a$ , $AC=b$ , $AB=c$ ។ តាង $p=\frac{a+b+c}{2}$ ជាកន្លះបរិមាត្រ ហើយ $r$ និង $R$ ជាកាំរង្វង់ចារឹកក្នុង និង កាំរង្វង់ចារឹកក្រៅនៃត្រីកោណ $ABC$ រៀងគ្នា ។

ចូរស្រាយបញ្ជាក់ថា :

ក. $ab+bc+ca=p^2+r^2+4rR$

ខ. $a^2+b^2+c^2=2p^2-2r^2-8rR$

គ. $a^3+b^3+c^3-3abc=2p(p^2-3r^2-12rR)$

21.គេឱ្យត្រីកោណ $ABC$ មួយ ។ $D$ ជាចំណុចមួយនៃជ្រុង $[BC]$ ដែល $\angle BAD=\alpha$ និង $\angle DAC=\beta$ ។

ចូរស្រាយបញ្ជាក់ថា $\frac{BC}{AD}=\frac{\sin\alpha}{\sin B}+\frac{\sin\beta}{\sin C}$ ?

## លំហាត់ទី១

គេមានត្រីកោណ **ABC** មួយកែងត្រង់ **C** ។ គេដឹងថា $AB = 10\ cm$

និង $\sin A + \sin B = \frac{7}{5}$ ។

ចូរកំណត់ជ្រុង **AC** និង **BC** រួចទាញរក $\tan A$ និង $\tan B$ ។

## ដំណោះស្រាយ

**កំណត់ជ្រុង AC និង BC**




តាង $BC = a$ , $AC = b$ , $AB = c = 10\ cm$

តាមទ្រឹស្តីបទពីតាគ័រក្នុងត្រីកោណកែង **ABC** គេមាន $a^2 + b^2 = c^2$

ដោយ $c = 10$ នោះ $a^2 + b^2 = 100$ (1)

ម្យ៉ាងទៀតតាមនិយមន័យ $\sin A = \frac{BC}{AB} = \frac{a}{10}$ ; $\sin B = \frac{AC}{AB} = \frac{b}{10}$

ដោយ $\sin A + \sin B = \frac{7}{5}$ នោះ $\frac{a}{10} + \frac{b}{10} = \frac{7}{5}$ ឬ $a + b = 14$ (2)

ទំនាក់ទំនង (1) អាចសរសេរ $(a+b)^2-2ab=100$

ឬ $ab=\frac{(a+b)^2}{2}-50=\frac{14^2}{2}-50=48 \quad (3)$

តាម (2) និង (3) គេបានប្រព័ន្ធសមីការ $\begin{cases} a+b=14 \\ ab=48 \end{cases}$

តាមទ្រឹស្តីបទវ្យែតនាំឱ្យ a និង b ជាឫសសមីការ $X^2-SX+P=0$

ឬ $X^2-14X+48=0$

$\Delta'=49-48=1$ គេទាញឫស $X_1=7-1=6$ ; $X_2=7+1=8$

ដូចនេះ $a=6$ , $b=8$ ឬ $a=8$ , $b=6$ ។

**ទាញរក $\tan A$ និង $\tan B$ :**

-ករណី $a=6$ , $b=8$ គេបាន :

$\tan A=\frac{a}{b}=\frac{6}{8}=\frac{3}{4}$ និង $\tan B=\frac{b}{a}=\frac{8}{6}=\frac{4}{3}$ ។

-ករណី $a=8$ , $b=6$ គេបាន :

$\tan A=\frac{a}{b}=\frac{8}{6}=\frac{4}{3}$ និង $\tan B=\frac{b}{a}=\frac{6}{8}=\frac{3}{4}$ ។

## លំហាត់ទី២

ដោយដឹងថា $\tan\alpha = \frac{5}{12}$ និង $0^o < \alpha < 90^o$ ។

ចូរគណនាតម្លៃនៃ $\cos\alpha$ , $\sin\alpha$ និង $\cot\alpha$ ។

## ដំណោះស្រាយ

គណនាតម្លៃនៃ $\cos\alpha$ , $\sin\alpha$ និង $\cot\alpha$

គេមាន $\tan\alpha = \frac{5}{12}$ និង $0^o < \alpha < 90^o$

តាមទំនាក់ទំនង $1+\tan^2\alpha = \frac{1}{\cos^2\alpha}$

គេទាញ $\cos^2\alpha = \frac{1}{1+\tan^2\alpha} = \frac{1}{1+\left(\frac{5}{12}\right)^2} = \frac{144}{169}$

ដោយ $0^o < \alpha < 90^o$ នោះ $\cos\alpha > 0$

ដូចនេះ $\cos\alpha = \frac{12}{13}$ ។

ហើយតាមទំនាក់ទំនង $\tan\alpha = \frac{\sin\alpha}{\cos\alpha}$

គេទាញ $\sin\alpha = \tan\alpha\cos\alpha = \frac{5}{12}.\frac{12}{13} = \frac{5}{13}$ រួច $\cot\alpha = \frac{1}{\tan\alpha} = \frac{12}{5}$ ។

ដូចនេះ $\cos\alpha = \frac{12}{13}$ ; $\sin\alpha = \frac{5}{13}$ ; $\cot\alpha = \frac{12}{5}$ ។

## លំហាត់ទី៣

ចូរគណនា $A=\sqrt{\sin^4 x+4\cos^2 x}+\sqrt{\cos^4 x+4\sin^2 x}$

$$B=(a\sin x+b\cos x)^2+(a\cos x-b\sin x)^2$$

## ដំណោះស្រាយ

គណនា $A$ និង $B$

$A=\sqrt{\sin^4 x+4\cos^2 x}+\sqrt{\cos^4 x+4\sin^2 x}$

ដោយ $\sin^2 x+\cos^2 x=1$ នោះ $\sin^2 x=1-\cos^2 x$ ឬ $\cos^2 x=1-\sin^2 x$

គេបាន $A=\sqrt{\sin^4 x+4(1-\sin^2 x)}+\sqrt{\cos^4 x+4(1-\cos^2 x)}$

$=\sqrt{\sin^4 x-4\sin^2 x+4}+\sqrt{\cos^4 x-4\cos^2 x+4}$

$=\sqrt{(\sin^2 x-2)^2}+\sqrt{(\cos^2 x-2)^2}$

$=|\sin^2 x-2|+|\cos^2 x-2|$

ដោយ $0\le\sin^2 x\le 1$ និង $0\le\cos^2 x\le 1$

គេបាន $A=-(\sin^2 x-2)-(\cos^2 x-2)$

$=4-(\sin^2 x+\cos^2 x)=4-1=3$ ។

$B=(a\sin x+b\cos x)^2+(a\cos x-b\sin x)^2$

$=a^2(\sin^2 x+\cos^2 x)+b^2(\sin^2 x+\cos^2 x)$

$=a^2+b^2$

ដូចនេះ $A=3$ , $B=a^2+b^2$ ។

## លំហាត់ទី៤

គេដឹងថា $\tan x = \sqrt{\frac{b}{a}}$ ។

ចូរស្រាយថា $\frac{\cos^4 x}{a} + \frac{\sin^4 x}{b} = \frac{1}{a+b}$

## ដំណោះស្រាយ

ស្រាយថា $\frac{\cos^4 x}{a} + \frac{\sin^4 x}{b} = \frac{1}{a+b}$

គេមាន $\tan x = \sqrt{\frac{b}{a}}$ នាំឱ្យ $\tan^2 x = \frac{b}{a}$ ដោយ $\tan x = \frac{\cos x}{\sin x}$

គេបាន $\frac{\sin^2 x}{\cos^2 x} = \frac{b}{a}$ ឬ $\frac{\cos^2 x}{a} = \frac{\sin^2 x}{b} = \frac{\cos^2 x + \sin^2 x}{a+b} = \frac{1}{a+b}$

គេទាញ $\frac{\cos^2 x}{a} = \frac{1}{a+b}$ នាំឱ្យ $\frac{\cos^4}{a} = \frac{a}{(a+b)^2}$ (1)

ហើយ $\frac{\sin^2 x}{b} = \frac{1}{a+b}$ នាំឱ្យ $\frac{\sin^4}{b} = \frac{b}{(a+b)^2}$ (2)

បូកសមភាព (1) និង (2) អង្គ និង អង្គគេបាន :

$$\frac{\cos^4 x}{a} + \frac{\sin^4 x}{b} = \frac{a}{(a+b)^2} + \frac{b}{(a+b)^2} = \frac{a+b}{(a+b)^2} = \frac{1}{a+b}$$

ដូចនេះ $\frac{\cos^4 x}{a} + \frac{\sin^4 x}{b} = \frac{1}{a+b}$ ។

## លំហាត់ទី៥

គេដឹងថា $\sin x+\cos x=\frac{41}{29}$ ។

ចូរគណនាផលគុណ $\sin x.\cos x$ រួចទាញរក $\sin x$ និង $\cos x$ ។

## ដំណោះស្រាយ

គណនាផលគុណ $\sin x.\cos x$

គេមាន $(\sin x+\cos x)^2=\sin^2 x+2\sin x\cos x+\cos^2 x$

ដោយ $\sin x+\cos x=\frac{41}{29}$ និង $\sin^2 x+\cos^2 x=1$

គេបាន $\left(\frac{41}{29}\right)^2=1+2\sin x\cos x$ ឬ $2\sin x\cos x=\frac{41^2-29^2}{29^2}=\frac{840}{841}$

ដូចនេះ $\sin x.\cos x=\frac{420}{841}$ ។

ទាញរក $\sin x$ និង $\cos x$ :

ដោយគេមាន $\sin x+\cos x=\frac{41}{29}$ និង $\sin x.\cos x=\frac{420}{841}$ នោះ $\sin x$ និង $\cos x$

ជាឫសសមីការ $X^2-\frac{41}{29}X+\frac{420}{841}=0$ ។

បន្ទាប់ពីដោះស្រាយសមីការនេះគេបាន $X_1=\frac{20}{29}$ ; $X_2=\frac{21}{29}$

ដូចនេះ $\sin x=\frac{20}{29}$ ; $\cos x=\frac{21}{29}$ ឬ $\sin x=\frac{21}{29}$ ; $\cos x=\frac{20}{29}$ ។

## លំហាត់ទី៦

គេដឹងថា $\tan x+\cot x=a$ ដែល $0<x<90^{o}$ និង $a\geq 2$ ។

ចូរគណនា $\tan^{3}x+\cot^{3}x$ ជាអនុគមន៍នៃ $a$ ។

## ដំណោះស្រាយ

គណនា $\tan^{3}x+\cot^{3}x$ ជាអនុគមន៍នៃ $a$

គេមាន $\tan x+\cot x=a$

គេបាន $(\tan x+\cot x)^{2}=a^{2}$

$$\tan^{2}x+2\tan x\cot x+\cot^{2}x=a^{2}$$ ដោយ $\tan x\cot x=1$

គេទាញ $\tan^{2}x+\cot^{2}x=a^{2}-2$

តាមសមភាព $A^{3}+B^{3}=(A+B)(A^{2}-A.B+B^{2})$

គេបាន $\tan^{3}x+\cot^{3}x=(\tan x+\cot x)(\tan^{2}x-\tan x\cot x+\cot^{2}x)$

$$=a(a^{2}-2-1)=a(a^{2}-3)$$

ដូចនេះ $\tan^{3}x+\cot^{3}x=a^{3}-3a$ ។

## លំហាត់ទី៧

ចំពោះគ្រប់ $x \in IR$ ចូរស្រាយបញ្ជាក់សមភាព :

ក. $\sin^6 x + \cos^6 x = 1 - 3\sin^2 x\cos^2 x$

ខ. $\frac{1}{4}(\sin^8 x + \cos^8 x) - \frac{1}{2}(\sin^4 x + \cos^4 x) + \frac{1}{4} = \frac{1}{2}\sin^4 x\cos^4 x$

## ដំណោះស្រាយ

ស្រាយបញ្ជាក់សមភាព :

ក. $\sin^6 x + \cos^6 x = 1 - 3\sin^2 x\cos^2 x$

គេមាន $(a+b)^3 = a^3 + 3a^2b + 3ab^2 + b^3$

ឬ $a^3 + b^3 = (a+b)^3 - 3ab(a+b)$

យក $a = \sin^2 x$ និង $b = \cos^2 x$ គេបាន :

$$\sin^6 x + \cos^6 x = (\sin^2 x + \cos^2 x)^3 - 3\sin^2 x\cos^2 x(\sin^2 x + \cos^2 x)$$

ដោយ $\sin^2 x + \cos^2 x = 1$

ដូចនេះ $\sin^6 x + \cos^6 x = 1 - 3\sin^2 x\cos^2 x$ ។

ខ. $\frac{1}{4}(\sin^8 x + \cos^8 x) - \frac{1}{2}(\sin^4 x + \cos^4 x) + \frac{1}{4} = \frac{1}{2}\sin^4 x\cos^4 x$

គេមាន $(a+b)^2 = a^2 + 2ab + b^2$ ឬ $a^2 + b^2 = (a+b)^2 - 2ab$

ដូចគ្នាដែរ $a^4 + b^4 = (a^2 + b^2)^2 - 2a^2b^2$

ឬ $a^4 + b^4 = \left[(a+b)^2 - 2ab\right]^2 - 2a^2b^2$

ដោយយក $a = \sin^2 x$ និង $b = \cos^2 x$ គេបានសមភាព

$$\sin^4 x+\cos^4 x=(\sin^2 x+\cos^2 x)^2-2\sin^2 x\cos^2 x$$
$$=1-2\sin^2 x\cos^2 x$$

ហើយ

$$\sin^8 x+\cos^8 x=\left[(\sin^2 x+\cos^2 x)^2-2\sin^2 x\cos^2 x\right]^2-2\sin^4 x\cos^4 x$$
$$=(1-2\sin^2 x\cos^2 x)^2-2\sin^4 x\cos^4 x$$
$$=1-4\sin^2 x\cos^2 x+2\sin^4 x\cos^4 x$$

តាងអនុគមន៍

$$f(x)=\frac{1}{4}(\sin^8 x+\cos^8 x)-\frac{1}{2}(\sin^4 x+\cos^4 x)+\frac{1}{4}$$
$$=\frac{1}{4}(1-4\sin^2 x\cos^2 x+2\sin^4 x\cos^4 x)-\frac{1}{2}(1-2\sin^2 x\cos^2 x)+\frac{1}{4}$$
$$=\frac{1-4\sin^2 x\cos^2 x+2\sin^4 x\cos^4 x-2+4\sin^2 x\cos^2 x+1}{4}$$
$$=\frac{2\sin^4 x\cos^4 x}{4}=\frac{1}{2}\sin^4 x\cos^4 x$$

ដូចនេះ $\frac{1}{4}(\sin^8 x+\cos^8 x)-\frac{1}{2}(\sin^4 x+\cos^4 x)+\frac{1}{4}=\frac{1}{2}\sin^4 x\cos^4 x$ ។

## លំហាត់ទី៨

គេដឹងថា $\cos a = \dfrac{m}{n+p}$ , $\cos b = \dfrac{n}{p+m}$ , $\cos c = \dfrac{p}{m+n}$

ចូរគណនាកន្សោម :

$$M = \frac{\sin^2 a}{2+2\cos a-\sin^2 a}+\frac{\sin^2 b}{2+2\cos b-\sin^2 b}+\frac{\sin^2 c}{2+2\cos c-\sin^2 c}$$

## ដំណោះស្រាយ

គណនាកន្សោម :

$$M = \frac{\sin^2 a}{2+2\cos a-\sin^2 a}+\frac{\sin^2 b}{2+2\cos b-\sin^2 b}+\frac{\sin^2 c}{2+2\cos c-\sin^2 c}$$

គេមាន $\sin^2 a = 1-\cos^2 a = (1-\cos a)(1+\cos a)$

និង $2+2\cos a-\sin^2 a = 1+2\cos a+\cos^2 a = (1+\cos a)^2$

គេបាន $\dfrac{\sin^2 a}{2+2\cos a-\sin^2 a} = \dfrac{(1-\cos a)(1+\cos a)}{(1+\cos a)^2} = \dfrac{1-\cos a}{1+\cos a}$

ហើយ $\dfrac{\sin^2 b}{2+2\cos b-\sin^2 b} = \dfrac{1-\cos b}{1+\cos b}$ និង $\dfrac{\sin^2 c}{2+2\cos c-\sin^2 c} = \dfrac{1-\cos c}{1+\cos c}$

គេបាន $E = \dfrac{1-\cos a}{1+\cos a}+\dfrac{1-\cos b}{1+\cos b}+\dfrac{1-\cos c}{1+\cos c}$

$$= \frac{1-\frac{m}{n+p}}{1+\frac{m}{n+p}}+\frac{1-\frac{n}{p+m}}{1+\frac{n}{p+m}}+\frac{1-\frac{p}{m+n}}{1+\frac{p}{m+n}}$$

$$= \frac{n+p-m+p+m-n+m+n-p}{m+n+p} = 1$$

ដូចនេះ $E = 1$ ។

## លំហាត់ទី៩

ចូរស្រាយបញ្ជាក់ថា $|a\cos x+b\sin x|\le\sqrt{a^2+b^2}$

## ដំណោះស្រាយ

ស្រាយបញ្ជាក់ថា $|a\cos x+b\sin x|\le\sqrt{a^2+b^2}$

ឧបមាថា $|a\cos x+b\sin x|\le\sqrt{a^2+b^2}$ ពិត

សមមូល $(a\cos x+b\sin x)^2\le a^2+b^2$

ដោយ $\sin^2 x+\cos^2 x=1$ នោះគេបាន :

$$(a\cos x+b\sin x)^2\le(a^2+b^2)(\sin^2 x+\cos^2 x)$$

$$a^2\cos^2 x+2ab\sin x\cos x+b^2\sin^2 x\le a^2\sin^2 x+a^2\cos^2 x+b^2\sin^2 x+b^2\cos^2 x$$

ឬ $a^2\sin^2 x-2ab\sin x\cos x+b^2\cos^2 x\ge 0$

ឬ $(a\sin x-b\cos x)^2\ge 0$ ពិត

ដូចនេះ $|a\cos x+b\sin x|\le\sqrt{a^2+b^2}$ ពិត ។

*សម្គាល់ :*

គេមាន $(a\cos x+b\sin x)^2+(a\sin x-b\cos x)^2=a^2+b^2$

ដោយ $(a\sin x-b\cos x)^2\ge 0$ នោះគេទាញបាន :

$(a\cos x+b\sin x)^2\le a^2+b^2$ ឬ $|a\cos x+b\sin x|\le\sqrt{a^2+b^2}$ ពិត ។

## លំហាត់ទី១០

គេមានត្រីកោណ $ABC$ មួយដែល $BC = a$ , $AC = b$ , $AB = c$ ។

ចូរស្រាយបញ្ជាក់សមភាព

$$bc\cos A + ac\cos B + ab\cos C = \frac{a^2+b^2+c^2}{2}$$

## ដំណោះស្រាយ

ស្រាយបញ្ជាក់ $bc\cos A + ac\cos B + ab\cos C = \frac{a^2+b^2+c^2}{2}$




តាមទ្រឹស្តីបទកូស៊ីនូសគេមានទំនាក់ទំនង :

$$a^2 = b^2 + c^2 - 2bc\cos A \quad (1)$$
$$b^2 = c^2 + a^2 - 2ac\cos B \quad (2)$$
$$c^2 = a^2 + b^2 - 2ab\cos C \quad (3)$$

បូកទំនាក់ទំនង (1) , (2) & (3) អង្គនិងអង្គគេបាន :

$$a^2 + b^2 + c^2 = 2(a^2 + b^2 + c^2 - bc\cos A - ac\cos B - ab\cos C)$$

ដូចនេះ $bc\cos A + ac\cos B + ab\cos C = \frac{a^2+b^2+c^2}{2}$ ។

## លំហាត់ទី១១

គេមានត្រីកោណ ABC មួយដែល $BC = a$ , $AC = b$ , $AB = c$ ។

តាង R និង S រៀងគ្នាជាកាំ និង ផ្ទៃក្រឡានៃត្រីកោណ ABC នេះ ។

ចូរស្រាយថា $\frac{\cos A}{a}+\frac{\cos B}{b}+\frac{\cos C}{c}=\frac{R(\sin^2 A+\sin^2 B+\sin^2 C)}{4S}$

## ដំណោះស្រាយ

ស្រាយថា $\frac{\cos A}{a}+\frac{\cos B}{b}+\frac{\cos C}{c}=\frac{R(\sin^2 A+\sin^2 B+\sin^2 C)}{4S}$

តាមទ្រឹស្តីបទកូស៊ីនូស និង ស៊ីនូសអនុវត្តន៍ក្នុងត្រីកោណ ABC គេបាន :

$a^2 = b^2 + c^2 - 2bc\cos A$ ឬ $\frac{\cos A}{a}=\frac{b^2+c^2-a^2}{2abc}$

$\frac{a}{\sin A}=\frac{b}{\sin B}=\frac{c}{\sin C}=2R$ ឬ $\begin{cases} a = 2R\sin A \\ b = 2R\sin B \\ c = 2R\sin C \end{cases}$ និង $S=\frac{abc}{4R}$

គេបាន $\frac{\cos A}{a}=\frac{4R^2(\sin^2 B+\sin^2 C-\sin^2 A)}{8RS}$

ឬ $\frac{\cos A}{a}=\frac{R(\sin^2 B+\sin^2 C-\sin^2 A)}{4S}$ (1)

ដូចគ្នាដែរ $\frac{\cos B}{b}=\frac{R(\sin^2 A+\sin^2 C-\sin^2 B)}{4S}$ (2)

និង $\frac{\cos C}{c}=\frac{R(\sin^2 A+\sin^2 B-\sin^2 C)}{4S}$ (3)

បូកសមភាព (1),(2) &(3) គេបាន :

$\frac{\cos A}{a}+\frac{\cos B}{b}+\frac{\cos C}{c}=\frac{R(\sin^2 A+\sin^2 B+\sin^2 C)}{4S}$ ពិត ។

## លំហាត់ទី១២

ក្នុងគ្រប់ត្រីកោណ ABC ចូរស្រាយថា :

$$(1+\cos A)(1+\cos B)(1+\cos C)=\frac{(\sin A+\sin B+\sin C)^2}{2}$$

## ដំណោះស្រាយ

ស្រាយបញ្ជាក់ថា

$$(1+\cos A)(1+\cos B)(1+\cos C)=\frac{(\sin A+\sin B+\sin C)^2}{2}$$

តាងជ្រុង $BC=a$ , $AC=b$ , $AB=c$ និង $p=\frac{a+b+c}{2}$ ជាកន្លះបរិមាត្រ

យក R ជាកាំរង្វង់ចារឹកក្រៅ និង S ជាផ្ទៃក្រឡារបស់ $\Delta ABC$ ។

តាមទ្រឹស្តីបទកូស៊ីនូសគេមាន $a^2=b^2+c^2-2bc\cos A$

គេបាន $a^2=(b^2+2bc+c^2)-2bc(1+\cos A)$

គេទាញ $1+\cos A=\frac{(b+c)^2-a^2}{2bc}=\frac{(b+c+a)(b+c-a)}{2bc}$

ដោយ $p=\frac{a+b+c}{2}$ នោះ $a+b+c=2p$ និង $b+c-a=2(p-a)$

គេបាន $1+\cos A=\frac{4p(p-a)}{2bc}=\frac{2p(p-a)}{bc}$

ដូចគ្នាដែរ $1+\cos B=\frac{2p(p-b)}{ac}$ , $1+\cos C=\frac{2p(p-c)}{ab}$

គេបាន $(1+\cos A)(1+\cos B)(1+\cos C)=\frac{8p^2.p(p-a)(p-b)(p-c)}{(abc)^2}$ (1)

តាមរូបមន្តហេរ៉ុង $S=\sqrt{p(p-a)(p-b)(p-c)}=\frac{abc}{4R}$

គេទាញ $\frac{p(p-a)(p-b)(p-c)}{(abc)^2}=\frac{1}{16R^2}$ (2)

យកទំនាក់ទំនង (2) ជំនួសក្នុង (1) គេបាន :

$$(1+\cos A)(1+\cos B)(1+\cos C)=\frac{8p^2}{16R^2}=\frac{1}{2}.\left(\frac{p}{R}\right)^2 \quad (3)$$

តាមទ្រឹស្តីបទស៊ីនុស $\frac{a}{\sin A}=\frac{b}{\sin B}=\frac{c}{\sin C}=2R$

គេទាញ $\sin A+\sin B+\sin C=\frac{a+b+c}{2R}=\frac{2p}{2R}=\frac{p}{R}$ (4)

តាម (3) និង (4) គេបានទំនាក់ទំនង :

$$(1+\cos A)(1+\cos B)(1+\cos C)=\frac{(\sin A+\sin B+\sin C)^2}{2}$$ ពិត ។

**សម្គាល់** : គេអាចសួរបន្ថែមទៀតដោយឱ្យស្រាយបញ្ជាក់ថា :

$$\left(1+\frac{\cos A+\cos B+\cos C}{3}\right)^3\geq\left(\frac{\sin A+\sin B+\sin C}{\sqrt{2}}\right)^2$$

ដោយប្រើវិសមភាពមធ្យមនព្វន្ត មធ្យមធរណីមាត្រគេបាន :

$$(1+\cos A)(1+\cos B)(1+\cos C)\leq\left(\frac{1+\cos A+1+\cos B+1+\cos C}{3}\right)^3$$

ឬ $(1+\cos A)(1+\cos B)(1+\cos C)\leq\left(1+\frac{\cos A+\cos B+\cos C}{3}\right)^3$

ដោយ $(1+\cos A)(1+\cos B)(1+\cos C)=\frac{(\sin A+\sin B+\sin C)^2}{2}$

ដូចនេះ $\left(1+\frac{\cos A+\cos B+\cos C}{3}\right)^3\geq\left(\frac{\sin A+\sin B+\sin C}{\sqrt{2}}\right)^2$ ពិត ។

## លំហាត់ទី១៣

ក្នុងគ្រប់ត្រីកោណចូរស្រាយថា :

$$(1-\cos A)(1-\cos B)(1-\cos C)=8\left(\frac{(p-a)(p-b)(p-c)}{abc}\right)^2$$

ដែល $a$ , $b$ , $c$ ជាជ្រុងត្រីកោណ $ABC$ និង $p=\frac{a+b+c}{2}$ ។

## ដំណោះស្រាយ

ស្រាយបញ្ជាក់ថា

$$(1-\cos A)(1-\cos B)(1-\cos C)=8\left(\frac{(p-a)(p-b)(p-c)}{abc}\right)^2$$

តាមទ្រឹស្តីបទកូស៊ីនូសគេមាន $a^2=b^2+c^2-2bc\cos A$

គេបាន $a^2=(b^2-2bc+c^2)+2bc(1-\cos A)$

គេទាញ $1-\cos A=\frac{a^2-(b-c)^2}{2bc}=\frac{(a+b-c)(a-b+c)}{2bc}$

ដោយ $p=\frac{a+b+c}{2}$ នោះ $a+b-c=2(p-c)$ និង $a-b+c=2(p-b)$

គេបាន $1-\cos A=\frac{4(p-b)(p-c)}{2bc}=\frac{2(p-b)(p-c)}{bc}$

ដូចគ្នាដែរ $1-\cos B=\frac{2(p-a)(p-c)}{ac};1-\cos C=\frac{2(p-a)(p-b)}{ab}$

ដូចនេះ $(1-\cos A)(1-\cos B)(1-\cos C)=8\left(\frac{(p-a)(p-b)(p-c)}{abc}\right)^2$ ពិត

## លំហាត់ទី១៤

គេឱ្យត្រីកោណ **ABC** មួយ ។

ក. ចូរស្រាយបញ្ជាក់ថា $1-\cos A \le \frac{a^2}{2bc}$

ដែល **a , b , c** ជាជ្រុងត្រីកោណ **ABC** ។

ខ. ទាញបញ្ជាក់ថា $(1-\cos A)(1-\cos B)(1-\cos C) \le \frac{1}{8}$

## ដំណោះស្រាយ

ក.ស្រាយបញ្ជាក់ថា $1-\cos A \le \frac{a^2}{2bc}$

តាមទ្រឹស្តីបទស៊ីនូសគេមាន $a^2 = b^2 + c^2 - 2bc\cos A$

តាមវិសមភាពមធ្យមនព្វន្ត មធ្យមធរណីមាត្រគេមាន $b^2 + c^2 \ge 2bc$

គេទាញ $a^2 \ge 2bc - 2bc\cos A = 2bc(1-\cos A)$

ដូចនេះ $1-\cos A \le \frac{a^2}{2bc}$ ។

ខ. ទាញបញ្ជាក់ថា $(1-\cos A)(1-\cos B)(1-\cos C) \le \frac{1}{8}$

តាមសម្រាយខាងលើគេមាន $1-\cos A \le \frac{a^2}{2bc}$ **(1)**

ស្រាយដូចគ្នាដែរ $1-\cos B \le \frac{b^2}{2ac}$ **(2)** និង $1-\cos C \le \frac{c^2}{2ab}$ **(3)**

គុណវិសមភាព **(1) , (2) , (3)** អង្គ និង អង្គគេទទួលបាន **:**

$(1-\cos A)(1-\cos B)(1-\cos C) \le \frac{1}{8}$ ពិត ។

## លំហាត់ទី១៥

គេឱ្យត្រីកោណ **ABC** មួយ ។

ក. ចូរស្រាយបញ្ជាក់ថា $\sin^2 A = \sin^2 B + \sin^2 C - 2\sin B \sin C \cos A$

ខ. ទាញបញ្ជាក់ថា :

$$\cot A + \cot B + \cot C = \frac{\sin^2 A + \sin^2 B + \sin^2 C}{2\sin A \sin B \sin C}$$

## ដំណោះស្រាយ

ក.ស្រាយបញ្ជាក់ថា $\sin^2 A = \sin^2 B + \sin^2 C - 2\sin B \sin C \cos A$

តាង **a , b , c** ជាជ្រុងត្រីកោណ **ABC** និង **R** ជាកាំរង្វង់ចារឹកក្រៅត្រីកោណ។

តាមទ្រឹស្តីបទស៊ីនូស $\frac{a}{\sin A} = \frac{b}{\sin B} = \frac{c}{\sin C} = 2R$

គេទាញ $\begin{cases} a = 2R\sin A \\ b = 2r\sin B \quad (1) \\ c = 2R\sin C \end{cases}$

តាមទ្រឹស្តីបទកូស៊ីនូស $a^2 = b^2 + c^2 - 2bc\cos A \quad (2)$

យក **(1)** ជំនួសក្នុង **(2)** គេបាន :

$$4R^2 \sin^2 A = 4R^2(\sin^2 B + \sin^2 C - 2\sin B \sin C \cos A)$$

សម្រួល $4R^2$ ក្នុងអង្គទាំងពីរនៃសមភាពគេបាន :

$\sin^2 A = \sin^2 B + \sin^2 C - 2\sin B \sin C \cos A$ ពិត

ដូចនេះ $\sin^2 A = \sin^2 B + \sin^2 C - 2\sin B \sin C \cos A$ ។

ខ. ទាញបញ្ជាក់ថា :

$$\cot A+\cot B+\cot C=\frac{\sin^2 A+\sin^2 B+\sin^2 C}{2\sin A\sin B\sin C}$$

តាមសម្រាយខាងលើគេមាន $\sin^2 A=\sin^2 B+\sin^2 C-2\sin B\sin C\cos A$

គេទាញ $\cos A=\dfrac{\sin^2 B+\sin^2 C-\sin^2 A}{2\sin B\sin C}$ ដោយ $\cot A=\dfrac{\cos A}{\sin A}$

គេបាន $\cot A=\dfrac{\sin^2 B+\sin^2 C-\sin^2 A}{2\sin A\sin B\sin C}$ **(i)**

ស្រាយដូចគ្នាដែរគេទទួលបាន $\cot B=\dfrac{\sin^2 A+\sin^2 C-\sin^2 B}{2\sin A\sin B\sin C}$ **(ii)**

និង $\cot C=\dfrac{\sin^2 A+\sin^2 B-\sin^2 C}{2\sin A\sin B\sin C}$ **(iii)**

ធ្វើផលបូកសមភាព **(i) , (ii) & (iii)** គេបាន :

$$\cot A+\cot B+\cot C=\frac{\sin^2 A+\sin^2 B+\sin^2 C}{2\sin A\sin B\sin C}$$ ពិត

ដូចនេះ $\cot A+\cot B+\cot C=\dfrac{\sin^2 A+\sin^2 B+\sin^2 C}{2\sin A\sin B\sin C}$ ។

## លំហាត់ទី១៦

គេឱ្យត្រីកោណ **ABC** មួយមានមុំ **A,B,C** ជាមុំស្រួចដែលផ្ទៀងផ្ទាត់សមភាព

$$\cot A+\cot B+\cot C=\frac{1}{2}\left(\frac{1}{\sin A}+\frac{1}{\sin B}+\frac{1}{\sin C}\right)$$ ។

ចូរស្រាយថា **ABC** ជាត្រីកោណសមង្ស ?

## ដំណោះស្រាយ

ស្រាយថា **ABC** ជាត្រីកោណសមង្ស

តាង **a , b , c** ជាជ្រុង និង **S** ជាផ្ទៃក្រឡានៃត្រីកោណ **ABC**

គេមាន $S=\frac{1}{2}bc\sin A=\frac{1}{2}ac\sin B=\frac{1}{2}ab\sin C$

គេទាញបាន $\sin A=\frac{2S}{bc}$ , $\sin B=\frac{2S}{ac}$ , $\mathrm{sib}C=\frac{2S}{ab}$

គេបាន $\cot A=\frac{\cos A}{\sin A}=\frac{\frac{b^2+c^2-a^2}{2bc}}{\frac{2S}{bc}}=\frac{b^2+c^2-a^2}{4S}$

ហើយ $\cot B=\frac{a^2+c^2-b^2}{4S}$ , $\cot C=\frac{a^2+b^2-c^2}{4S}$

គេបាន $\cot A+\cot B+\cot C=\frac{a^2+b^2+c^2}{4S}$ **(1)**

ម្យ៉ាងទៀត $\frac{1}{\sin A}+\frac{1}{\sin B}+\frac{1}{\sin C}=\frac{bc+ca+ab}{2S}$ **(2)**

តាមសម្មតិកម្ម $\cot A+\cot B+\cot C=\frac{1}{2}\left(\frac{1}{\sin A}+\frac{1}{\sin B}+\frac{1}{\sin C}\right)$ **(3)**

យកសមីការ (1) & (2) ជំនួសក្នុង (3) គេបាន :

$$\frac{a^2+b^2+c^2}{4S}=\frac{ab+bc+ca}{4S}$$

ឬ $a^2+b^2+c^2=ab+bc+ca$

ទំនាក់ទំនងនេះសមមូល $(a-b)^2+(b-c)^2+(c-a)^2=0$

គេទាញ $\begin{cases}a-b=0\\ b-c=0\\ c-a=0\end{cases}$ នាំឱ្យ $a=b=c$ ។

ដោយត្រីកោណ ABC មានជ្រុងបីស្មើគ្នាវាជាត្រីកោណសមង្ស័ ។

សម្គាល់ :

ដោយគេអាចស្រាយថា $\cot A+\cot B+\cot C=\dfrac{\sin^2 A+\sin^2 B+\sin^2 C}{2\sin A\sin B\sin C}$

ហើយសម្មតិកម្ម $\cot A+\cot B+\cot C=\dfrac{1}{2}\left(\dfrac{1}{\sin A}+\dfrac{1}{\sin B}+\dfrac{1}{\sin C}\right)$

គេទាញបានសមីការ :

$$\frac{\sin^2 A+\sin^2 B+\sin^2 C}{2\sin A\sin B\sin C}=\frac{1}{2}\left(\frac{1}{\sin A}+\frac{1}{\sin B}+\frac{1}{\sin C}\right)$$

$$\sin^2 A+\sin^2 B+\sin^2 C=\sin A\sin B+\sin B\sin C+\sin C\sin A$$

$$(\sin A-\sin B)^2+(\sin B-\sin C)^2+(\sin C-\sin A)^2=0$$

គេទាញ $\begin{cases}\sin A-\sin B=0\\ \sin B-\sin C=0\\ \sin C-\sin A=0\end{cases}$ នាំឱ្យ $\sin A=\sin B=\sin C$

ឬ $A=B=C$ នោះ ABC ជាត្រីកោណសមង្ស័ ។

## លំហាត់ទី១៧

គេឱ្យត្រីកោណ **ABC** មួយមានជ្រុង $AB = 5cm$ និងមានផ្ទៃក្រឡា $S = 6cm^2$ ។

គណនាតម្លៃ $\cot A + \cot B$ ។

## ដំណោះស្រាយ

គណនាតម្លៃ $\cot A + \cot B$




សង់កំពស់ **CH** នៃ $\Delta ABC$ ។

គេមាន $\cot A = \dfrac{AH}{CH}$ និង $\cot C = \dfrac{HB}{CH}$

គេបាន $\cot A + \cot B = \dfrac{AH + HB}{CH} = \dfrac{AB}{CH} = \dfrac{AB^2}{AB.CH} = \dfrac{AB^2}{2S}$

ដោយ $AB = 5\ cm$ & $S = 6cm^2$

ដូចនេះ $\cot A + \cot B = \dfrac{25}{12}$ ។

## លំហាត់ទី១៨

តាង **R** ជាកាំរង្វង់ចារឹកក្នុង និង **S** ជាផ្ទៃក្រឡានៃត្រីកោណ **ABC** មួយ ។

ក. ចូរស្រាយថា $(\cot A+\cot B)(\cot B+\cot C)(\cot C+\cot A)=\frac{2R^2}{S}$

ខ. បើ **ABC** ជាមុំស្រួចនោះចូរទាញឱ្យបានថា : $\cos A\cos B\cos C\le\frac{1}{8}$ ។

## ដំណោះស្រាយ

ស្រាយថា $(\cot A+\cot B)(\cot B+\cot C)(\cot C+\cot A)=\frac{2R^2}{S}$




គូសកំពស់ $AA'=h_a$ នៃ $\Delta ABC$ ។ តាង $BC=a$ , $AC=b$ , $AB=c$ ។

ក្នុងត្រីកោណកែង $ABA'$ & $AA'C$ គេមាន $\cot B=\frac{BA'}{AA'}$ ; $\cot C=\frac{A'C}{AA'}$

គេបាន $\cot B+\cot C=\frac{BA'+A'C}{AA'}=\frac{a}{h_a}=\frac{a^2}{2S}$ ដែល S ជាផ្ទៃក្រឡា $\Delta ABC$

ដូចគ្នាដែរ $\cot C+\cot A=\frac{b^2}{2S}$ , $\cot A+\cot B=\frac{c^2}{2S}$

គេបាន $(\cot A+\cot B)(\cot B+\cot C)(\cot C+\cot A)=\frac{a^2b^2c^2}{8S^3}$

ដោយ $S=\frac{abc}{4R}$ នោះ $abc=4RS$

គេបាន $(\cot A+\cot B)(\cot B+\cot C)(\cot C+\cot A)=\frac{16R^2S^2}{8S^3}$

ដូចនេះ $(\cot A+\cot B)(\cot B+\cot C)(\cot C+\cot A)=\frac{2R^2}{S}$ ។

ខ. ទាញ ឱ្យបានថា : $\cos A\cos B\cos C\le\frac{1}{8}$

តាមសម្រាយខាងលើគេមាន :

$$(\cot A+\cot B)(\cot B+\cot C)(\cot C+\cot A)=\frac{2R^2}{S}\quad (i)$$

បើ $ABC$ ជាមុំស្រួចនោះ $\cot A>0$ , $\cot B>0$ , $\cot C>0$

តាមវិសមភាព មធ្យមនព្វន្ត មធ្យមធរណីមាត្រគេមាន :

$\cot A+\cot B\ge 2\sqrt{\cot A\cot B}$ , $\cot B+\cot C\ge 2\sqrt{\cot B\cot C}$

$\cot C+\cot A\ge 2\sqrt{\cot C\cot A}$

គុណវិសមភាពខាងលើនេះ អង្គ និង អង្គ គេបាន

$$(\cot A+\cot B)(\cot B+\cot C)(\cot C+\cot A)\ge 8\cot A\cot B\cot C\ (ii)$$

តាម $(i)\&(ii)$ គេទាញបាន $8\cot A\cot B\cot C\le\frac{2R^2}{S}$

តែ $S=\frac{abc}{4R}=\frac{8R^3\sin A\sin B\sin C}{4R}=2R^2\sin A\sin B\sin C$

គេបាន $8\cot A\cot B\cot C\le\frac{2R^2}{2R^2\sin A\sin B\sin C}$

ដូចនេះ $\cos A\cos B\cos C\le\frac{1}{8}$ ។

## លំហាត់ទី១៩

គេឱ្យត្រីកោណ **ABC** មួយមានជ្រុង $\mathbf{BC=a}$ , $\mathbf{AC=b}$ , $\mathbf{AB=c}$ ចារឹកក្នុងរង្វង់មួយមានផ្ចិត **O** និង កាំ **R** ។ តាង **S** និង $\mathbf{S_{OBC}}$ ជាផ្ទៃក្រឡានៃ $\mathbf{\Delta OBC}$ និង $\mathbf{\Delta ABC}$ រៀងគ្នា ។ សន្មតថា **A,B,C** ជាមុំស្រួច ។

ក. ចូរស្រាយថា $\mathbf{S_{OBC}=\frac{1}{4}a^2\cot A}$ ។

ខ. ចូរទាញបង្ហាញថា $\mathbf{a^2\cot A+b^2\cot B+c^2\cot C=4S}$ ។

គ. ចូរទាញបង្ហាញថា $\mathbf{a\cos A+b\cos B+c\cos C=\frac{abc}{2R^2}}$ ។

## ដំណោះស្រាយ

ក. ស្រាយថា $\mathbf{S_{OBC}=\frac{1}{4}a^2\cot A}$




តាង **K** ជាចំណុចកណ្ដាលនៃជ្រុង **[BC]** នោះ $\mathbf{[OK]\perp[BC]}$ ។

គេមាន $\mathbf{\angle BOK=\frac{\angle BOC}{2}=\angle BAC=\angle A}$ ។

ក្នុងត្រីកោណកែង **OBK** គេមាន :

$$\cot\angle BOK = \cot A = \frac{OK}{BK} = \frac{2OK}{BC} = \frac{2OK}{a}$$

គេទាញ $OK = \frac{1}{2}a\cot A$ ។

ក្រឡាផ្ទៃនៃត្រីកោណ **OBC** គឺ $S_{OBC} = \frac{1}{2}BC.OK = \frac{1}{4}a^2\cot A$ ពិត

ដូចនេះ $S_{OBC} = \frac{1}{4}a^2\cot A$ ។

ខ. ទាញបង្ហាញថា $a^2\cot A + b^2\cot B + c^2\cot C = 4S$

តាមសម្រាយខាងលើគេមាន $S_{OBC} = \frac{1}{4}a^2\cot A$

ដូចគ្នាដែរ $S_{OCA} = \frac{1}{4}b^2\cot B$ និង $S_{OAB} = \frac{1}{4}c^2\cot C$

ដោយ $S = S_{OBC} + S_{OCA} + S_{OAB}$

គេបាន $S = \frac{1}{4}(a^2\cot A + b^2\cot B + c^2\cot C)$

ដូចនេះ $a^2\cot A + b^2\cot B + c^2\cot C = 4S$ ។

គ. ទាញបង្ហាញថា $a\cos A + b\cos B + c\cos C = \frac{abc}{2R^2}$

គេមាន $a^2\cot A + b^2\cot B + c^2\cot C = 4S = \frac{abc}{R}$ ព្រោះ $S = \frac{abc}{4R}$

ដោយ $a^2\cot A = \frac{a}{\sin A}.a\cos A = 2Ra\cos A$ , $b^2\cot B = 2Rb\cos B$

នោះគេបាន $a\cos A + b\cos B + c\cos C = \frac{abc}{2R^2}$ ។

## លំហាត់ទី២០

គេឱ្យត្រីកោណ **ABC** មួយមានជ្រុង $BC = a$ , $AC = b$ , $AB = c$ ។

តាង $p = \dfrac{a+b+c}{2}$ ជាកន្លះបរិមាត្រ ហើយ $r$ និង $R$ ជាកាំរង្វង់ចារឹកក្នុង និង កាំរង្វង់ចារឹកក្រៅនៃត្រីកោណ **ABC** រៀងគ្នា ។

ចូរស្រាយបញ្ជាក់ថា :

ក. $ab + bc + ca = p^2 + r^2 + 4rR$

ខ. $a^2 + b^2 + c^2 = 2p^2 - 2r^2 - 8rR$

គ. $a^3 + b^3 + c^3 - 3abc = 2p(p^2 - 3r^2 - 12rR)$

## ដំណោះស្រាយ

ស្រាយបញ្ជាក់ថា :

ក. $ab + bc + ca = p^2 + r^2 + 4rR$

តាមរូបមន្តហេរ៉ុង $S = \sqrt{p(p-a)(p-b)(p-c)}$

តែគេមាន $S = pr$ នោះគេបានសមីការ

$pr = \sqrt{p(p-a)(p-b)(p-c)}$

លើកអង្គទាំងពីរជាការេគេបាន :

$p^2r^2 = p(p-a)(p-b)(p-c)$

$pr^2 = p^3 - (a+b+c)p^2 + (ab+bc+ca)p - abc$

ដោយ $a+b+c = 2p$ ហើយ $abc = 4R.S = 4R.pr$

$pr^2 = p^3 - 2p^3 + (ab + bc + ca)p - 4R.pr$

$pr^2 = -p^3 + (ab + bc + ca)p - 4rRp$

គេទាញ $ab + bc + ca = \dfrac{pr^2 + p^3 + 4rRp}{p}$

ដូចនេះ $ab + bc + ca = p^2 + r^2 + 4rR$

ខ. $a^2 + b^2 + c^2 = 2p^2 - 2r^2 - 8rR$

គេមាន $a^2 + b^2 + c^2 = (a + b + c)^2 - 2(ab + bc + ca)$

ដោយ $a + b + c = 2p$ និង $ab + bc + ca = p^2 + r^2 + 4rR$

ដូចនេះ $a^2 + b^2 + c^2 = 2p^2 - 2r^2 - 8rR$ ។

គ. $a^3 + b^3 + c^3 - 3abc = 2p(p^2 - 3r^2 - 12rR)$

គេមានសមភាព :

$a^3 + b^3 + c^3 - 3abc = (a + b + c)[(a + b + c)^2 - 3(ab + bc + ca)]$

ដោយ $a + b + c = 2p$ និង $ab + bc + ca = p^2 + r^2 + 4rR$

ដូចនេះ $a^3 + b^3 + c^3 - 3abc = 2p(p^2 - 3r^2 - 12rR)$ ។

## លំហាត់ទី២១

គេឱ្យត្រីកោណ **ABC** មួយ ។ **D** ជាចំណុចមួយនៃជ្រុង **[BC]** ដែល $\angle BAD = \alpha$ និង $\angle DAC = \beta$ ។

ចូរស្រាយបញ្ជាក់ថា $\frac{BC}{AD} = \frac{\sin\alpha}{\sin B} + \frac{\sin\beta}{\sin C}$ ?

## ដំណោះស្រាយ

ស្រាយបញ្ជាក់ថា $\frac{BC}{AD} = \frac{\sin\alpha}{\sin B} + \frac{\sin\beta}{\sin C}$




តាមទ្រឹស្តីបទស៊ីនូសអនុវត្តន៍

ក្នុង $\Delta ABD$ & $\Delta ADC$

គេមាន $\frac{BD}{\sin\alpha} = \frac{AD}{\sin B}$

ឬ $BD = \frac{\sin\alpha}{\sin B}.AD$ (1)

ហើយ $\frac{DC}{\sin\beta} = \frac{AD}{\sin C}$

ឬ $DC = \frac{\sin\beta}{\sin C}.AD$ (2)

បូកទំនាក់ទំនង (1) & (2) គេបាន $BD + DC = \left(\frac{\sin\alpha}{\sin B} + \frac{\sin\beta}{\sin C}\right).AD$

ដោយ $BD + DC = BC$ នោះ $BC = \left(\frac{\sin\alpha}{\sin B} + \frac{\sin\beta}{\sin C}\right).AD$

ដូចនេះ $\frac{BC}{AD} = \frac{\sin\alpha}{\sin B} + \frac{\sin\beta}{\sin C}$ ។